កិច្ចព្រមព្រៀងជាលាយលក្ខណ៍អក្សរស្របច្បាប់មួយ រវាងម្ចាស់ហ៊ុនទាំងអស់របស់ក្រុមហ៊ុន ដែលដាក់កម្រិតអំណាចទាំងស្រុង ឬ មួយផ្នែករបស់អភិបាលក្នុងការគ្រប់គ្រងអាជីវកម្ម និងកិច្ចការរបស់ក្រុមហ៊ុន គឺមានសុពលភាព ។

អ្នកទទួលការផ្ទេរភាគហ៊ុនដែលផ្អែកតាមការព្រមព្រៀងនោះជាឯកច្ឆន្ទរបស់ម្ចាស់ហ៊ុន ត្រូវចាត់ទុកជាភាគីនៃកិច្ចព្រមព្រៀងនោះ ។

ម្ចាស់ហ៊ុនដែលជាភាគីនៃកិច្ចព្រមព្រៀងជាឯកច្ឆន្ទបានទទួលនូវសិទ្ធិ ភារកិច្ចទាំងអស់របស់អភិបាលក្រុមហ៊ុន ដើម្បីគ្រប់គ្រងជំនួញ និងកិច្ចការក្រុមហ៊ុន ដែលមានទំនាក់ទំនងទៅនឹងកិច្ចព្រមព្រៀងនោះ ។ អភិបាលត្រូវបំពេញភារកិច្ច និង ការទទួលខុសត្រូវរបស់ខ្លួនតាមកិច្ចព្រមព្រៀងជាឯកច្ឆន្ទរបស់ម្ចាស់ហ៊ុន ។

កិច្ចព្រមព្រៀងជាឯកច្ឆន្ទរបស់ម្ចាស់ហ៊ុន ត្រូវធ្វើឡើងដោយសមាជិកហ៊ុន ។

កិច្ចព្រមព្រៀងជាឯកច្ឆន្ទរបស់ម្ចាស់ហ៊ុន ត្រូវរក្សាទុកក្នុងកំណត់ហេតុរបស់ក្រុមហ៊ុនដូចដែលបានចែងក្នុងមាត្រា ១០៩ ។

កិច្ចព្រមព្រៀងជាឯកច្ឆន្ទរបស់ម្ចាស់ហ៊ុន ត្រូវតែធ្វើឡើងជាលាយលក្ខណ៍អក្សរនៅលើប័ណ្ណភាគហ៊ុន ។

ឈ- របាយការណ៍ហិរញ្ញវត្ថុ

មាត្រា ២២៤.-

អភិបាលត្រូវបង្ហាញរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ នៅក្នុងមហាសន្និបាតម្ចាស់ហ៊ុនប្រចាំឆ្នាំ ។ របាយការណ៍នោះត្រូវមានទាំង :

ក- របាយការណ៍ហិរញ្ញវត្ថុ ដែលប្រៀបធៀបរវាងឆ្នាំសារពើពន្ធបច្ចុប្បន្ន និងឆ្នាំសារពើពន្ធឆ្នាំមុន ។ នៅក្នុងឆ្នាំដំបូងនៃអត្ថិភាពរបស់ក្រុមហ៊ុនរបាយការណ៍ហិរញ្ញវត្ថុត្រូវចាប់ផ្តើមពិនិត្យពីពេលក្រុមហ៊ុនមានអត្ថិភាព និងបញ្ចប់នៅកាលបរិច្ឆេទមិនលើសពី ៦ (ប្រាំមួយ)ខែ មុនមហាសន្និបាតប្រចាំឆ្នាំ ។

ខ- របាយការណ៍របស់សវនករ ។

គ- ព័ត៌មានផ្សេងទៀត ដែលធ្វើទៅតាមស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងលទ្ធផលដែលទទួលបានពីប្រតិបត្តិការរបស់ក្រុមហ៊ុន ដែលតម្រូវដោយលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ឬ កិច្ចព្រមព្រៀងជាឯកច្ឆន្ទនៃម្ចាស់ហ៊ុន ។

មាត្រា ២២៥.-

យោងតាមសំណើរបស់ខ្លួន ម្ចាស់ហ៊ុន ភ្នាក់ងារ និងអ្នកតំណាងស្របច្បាប់របស់ខ្លួន អាចត្រួតពិនិត្យរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ នៅក្នុងម៉ោងធ្វើការធម្មតារបស់ក្រុមហ៊ុន និងអាចដកស្រង់យករបាយការណ៍នោះបាន ដោយមិនគិតថ្លៃ ។

មាត្រា ២២៦.-

អភិបាលទទួលយល់ព្រមលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ហើយការយល់ព្រមនោះត្រូវមានហត្ថលេខារបស់អភិបាលម្នាក់ ឬ ច្រើននាក់ ។

ក្រុមហ៊ុនមិនត្រូវចេញឱ្យបោះផ្សាយ ឬ ធ្វើចរាចរឯកសារនៃរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំបានឡើយ ។ ក្រុមហ៊ុនអាចធ្វើកិច្ចការខាងលើបាន លុះត្រាតែរបាយការណ៍ហិរញ្ញវត្ថុនោះមានការយល់ព្រមពីក្រុមប្រឹក្សាភិបាល និង ត្រូវអមដោយរបាយការណ៍របស់សវនករផង ។

មាត្រា ២២៧.-

ក្រុមហ៊ុនត្រូវបញ្ជូនឯកសាររបាយការណ៍ហិរញ្ញវត្ថុនិងឯកសារស្វែងយល់ទាំងឡាយទៅគ្រប់ម្ចាស់ហ៊ុនយ៉ាងយូរ ២១ (ម្ភៃមួយ)ថ្ងៃ មុនមហាសន្និបាតម្ចាស់ហ៊ុនប្រចាំឆ្នាំ ឬមុនការចុះហត្ថលេខាលើសេចក្តីសម្រេចក្នុងមហាសន្និបាតប្រចាំឆ្នាំនោះ លើកលែងតែម្ចាស់ហ៊ុនណាដែលបានជូនដំណឹងទៅក្រុមហ៊ុនជាលាយលក្ខណ៍អក្សរថាខ្លួនមិនត្រូវការឯកសារទាំងនោះទេ ។

មាត្រា ២២៨.-

ក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលបានបោះចេញមូលបត្រប្រភេទណាមួយទៅសាធារណជន ដែលត្រូវបានកាន់កាប់ដោយបុគ្គលលើសពីម្នាក់ ត្រូវធ្វើ

ឯកសាររបាយការណ៍ហិរញ្ញវត្ថុ និងឯកសារពាក់ព័ន្ធទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ។

របាយការណ៍ និងឯកសារទាំងឡាយ ត្រូវផ្ញើទៅគ្រប់ម្ចាស់ហ៊ុនយ៉ាងយូរ ២១ (ម្ភៃមួយ)ថ្ងៃ មុនមហាសន្និបាតម្ចាស់ហ៊ុនប្រចាំឆ្នាំ ឬ ផ្ញើជាបន្ទាន់ បន្ទាប់ពីការចុះហត្ថលេខាលើសេចក្តីសម្រេចក្នុងមហាសន្និបាតប្រចាំឆ្នាំនោះ ។

មាត្រា ២២៩.-

ម្ចាស់ហ៊ុនត្រូវតែងតាំងសវនករមួយរូប ដោយសេចក្តីសម្រេចសាមញ្ញនៅក្នុងមហាសន្និបាតម្ចាស់ហ៊ុនប្រចាំឆ្នាំលើកទីមួយ និងនៅមហាសន្និបាតប្រចាំឆ្នាំនីមួយៗ ។

សវនករ ត្រូវកាន់តំណែងរហូតដល់ការបិទមហាសន្និបាតនៃឆ្នាំបន្ទាប់ ។

ប្រសិនបើសវនករថ្មីមិនបានតែងតាំងនៅក្នុងមហាសន្និបាតម្ចាស់ហ៊ុនទេ សវនករដែលកំពុងកាន់តំណែង ត្រូវបន្តរហូតដល់សវនករថ្មីត្រូវបានតែងតាំង ។

មាត្រា ២៣០.-

ម្ចាស់ហ៊ុននៃក្រុមហ៊ុនដែលមិនបានចេញមូលបត្រប្រភេទណាមួយទៅឱ្យសាធារណជន ឬ ដោយគ្មានមូលបត្រដែលកាន់ដោយបុគ្គលលើសពីម្នាក់ អាចធ្វើសេចក្តីសម្រេចមិនតែងតាំងសវនករបាន ។

មាត្រា ២៣១.-

សោហ៊ុយចំណាយសម្រាប់សវនករ អាចត្រូវបានកំណត់ឡើងដោយសេចក្តីសម្រេចសាមញ្ញរបស់ម្ចាស់ហ៊ុន ឬ បើមិនដូច្នេះទេ ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល ។

មាត្រា ២៣២.-

ម្ចាស់ហ៊ុនទាំងឡាយអាចដកហូតសវនករពីមុខតំណែងបាន លើកលែងតែសវនករត្រូវបានតែងតាំងដោយតុលាការ ឬ ដោយសេចក្តីសម្រេចសាមញ្ញនៅក្នុង

មហាសន្និបាតពិសេស ។ នៅក្នុងអង្គប្រជុំដូចគ្នានោះ ម្ចាស់ហ៊ុនអាចតែងតាំងសវនករជំនួសបាន ។

នៅពេលណា ដែលមានភាពទំនេរនៃតំណែងសវនករ ក្រុមប្រឹក្សាភិបាលត្រូវកោះប្រជុំមហាសន្និបាតពិសេសនៃម្ចាស់ហ៊ុន ដើម្បីបំពេញភាពនៅទំនេរនោះ ដោយត្រូវធ្វើឡើងក្នុងរយៈពេល ២១ (ម្ភៃមួយ)ថ្ងៃ បន្ទាប់ពីមានភាពទំនេរនោះ ។

សវនករដែលត្រូវតែងតាំងដើម្បីបំពេញភាពទំនេរនោះ ត្រូវកាន់កាប់តំណែងបន្តជំនួសអាណត្តិដែលមិនទាន់ផុតកំណត់របស់សវនករមុន ។

មាត្រា ២៣៣.-

ប្រសិនបើក្រុមហ៊ុនមិនទាន់មានសវនករ តាមការស្នើសុំរបស់ម្ចាស់ហ៊ុន ឬ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម តុលាការអាចតែងតាំង និងដាក់កំណត់ដោះស្រាយចំណាយសម្រាប់សវនករ ដែលបានកាន់តំណែងរហូតដល់សវនករថ្មីត្រូវបានតែងតាំងដោយម្ចាស់ហ៊ុនទាំងឡាយ ។

មាត្រា ២៣៤.-

សវនករត្រូវធ្វើការត្រួតពិនិត្យ លើចំណុចដែលខ្លួនយល់ថាចាំបាច់ដើម្បីរាយការណ៍ជូនម្ចាស់ហ៊ុនទាំងឡាយ លើរបាយការណ៍ហិរញ្ញវត្ថុដែលបានតម្រូវដោយច្បាប់នេះ ។

តាមការស្នើសុំរបស់សវនករនៃក្រុមហ៊ុនមួយ អភិបាលមុន ឬ អភិបាលបច្ចុប្បន្ន អ្នកគ្រប់គ្រងក្រុមហ៊ុន បុគ្គលិក ឬ ភ្នាក់ងាររបស់ក្រុមហ៊ុន ត្រូវផ្តល់ព័ត៌មានការបកស្រាយបំភ្លឺ និងសៀវភៅបញ្ជី និងកំណត់ហេតុទាំងឡាយ ដែលសវនករនោះចាត់ទុកជាការចាំបាច់សម្រាប់ការបំពេញមុខងាររបស់គេ ។

សវនកររបស់ក្រុមហ៊ុន មានសិទ្ធិទទួលលិខិតជូនដំណឹងនៃមហាសន្និបាត ម្ចាស់ហ៊ុន និងចូលរួមដើម្បីដឹងព្ធន្ធវកម្មវត្ថុ ដែលទាក់ទងទៅនឹងភារកិច្ចរបស់ខ្លួនជាសវនករដែលចេញសោហ៊ុយចំណាយដោយក្រុមហ៊ុន ។

ប្រសិនបើអភិបាល ឬ ម្ចាស់ហ៊ុន ទោះបីជាម្ចាស់ហ៊ុននោះគ្មានសិទ្ធិបោះឆ្នោតក្នុងអង្គប្រជុំក៏ដោយ បានផ្ញើនដំណឹងជាលាយលក្ខណ៍អក្សរទៅសវនករបច្ចុប្បន្ន ឬ ពីមុនក្នុងរយៈពេលយ៉ាងតិច ១០(ដប់)ថ្ងៃ មុនមហាសន្និបាត សវនករបច្ចុប្បន្ន ឬសវនករពីមុនត្រូវចូលរួមប្រជុំដែលចេញសោហ៊ុយចំណាយដោយក្រុមហ៊ុននោះនឹងត្រូវឆ្លើយនូវសំណួរដែលពាក់ព័ន្ធទៅនឹងភារកិច្ចរបស់ខ្លួនដែលជាសវនករ ។

៣- ការកែប្រែលក្ខន្តិកៈក្រុមហ៊ុន

មាត្រា ២៣៥.-

ក្រុមហ៊ុនមូលធនអាចធ្វើការកែប្រែលក្ខន្តិកៈរបស់ខ្លួនគ្រប់ពេលវេលាបាន ។

មាត្រា ២៣៦.-

ក្រុមហ៊ុនមូលធនត្រូវធ្វើការកែប្រែលក្ខន្តិកៈតាមសេចក្ដីសម្រេចពិសេស។ អ្នកកាន់កាប់ភាគហ៊ុននៃប្រភេទ ឬ ស៊េរីនៃប័ណ្ណភាគហ៊ុនមានសិទ្ធិបោះឆ្នោតជាប្រភេទ ឬ ជាស៊េរីដាច់ដោយឡែកពីគ្នា នៅពេលដែលសេចក្ដីស្នើសុំធ្វើការកែប្រែលក្ខន្តិកៈនោះក្នុងគោលបំណង :

១- បន្ថែម កែប្រែ ឬ ដកហូតនូវសិទ្ធិ ឯកសិទ្ធិ ការរឹតត្បិតទាំងឡាយដែលភ្ជាប់ទៅនឹងប្រភេទ ឬ ស៊េរីនៃប័ណ្ណភាគហ៊ុន ។

២- បង្កើន ឬបន្ថយនូវចំនួនអតិបរមានៃប័ណ្ណភាគហ៊ុន តាមប្រភេទ ឬ ស៊េរីនៃប័ណ្ណភាគហ៊ុននោះ ។

៣- បង្កើននូវចំនួនអតិបរមានៃប័ណ្ណភាគហ៊ុន ដែលមានសិទ្ធិចំពោះប្រភេទ ឬ ស៊េរីដែលមានសិទ្ធិ ឬ ឯកសិទ្ធិស្មើ ឬ ក៏លើសពីប័ណ្ណភាគហ៊ុនរបស់អ្នកកាន់កាប់នោះ ។

៤- បង្កើតប្រភេទថ្មីនៃប័ណ្ណដែលស្មើ ឬ លើសពីប័ណ្ណភាគហ៊ុននៃប្រភេទ ឬ ស៊េរីរបស់អ្នកកាន់កាប់នោះ ។

៥- បង្កើតប្រភេទនៃប័ណ្ណភាគហ៊ុនណាមួយដែលមានសិទ្ធិ ឬ ឯកសិទ្ធិតូចជាង ឬ ស្មើ ឬ លើសប័ណ្ណភាគហ៊ុនរបស់អ្នកកាន់កាប់នោះ ។

៦- បន្ថយគណនីដើមទុនចុះបញ្ជីនៃប្រភេទ ឬ សេរីនៃប័ណ្ណភាគហ៊ុនរបស់អ្នកកាន់កាប់នោះ ។

ទោះបីជាលក្ខន្តិកៈក្រុមហ៊ុនចែងថាប្រភេទ ឬ សេរីនៃប័ណ្ណភាគហ៊ុនជាក់លាក់មួយគ្មានសិទ្ធិក្នុងការបោះឆ្នោតក៏ដោយ ក៏ប្រភេទ ឬ សេរីនៃប័ណ្ណភាគហ៊ុន នោះមានសិទ្ធិបោះឆ្នោតជានិច្ចទៅតាមប្រភេទ ឬ សេរីដាច់ដោយឡែកពីគ្នា លើការកែប្រែណាមួយ ទៅតាមលក្ខន្តិកៈរបស់ក្រុមហ៊ុន ដែលកែប្រែដោយផ្ទាល់ ឬ ដោយប្រយោល ឬ ប៉ះពាល់ទៅនឹង សិទ្ធិ ឯកសិទ្ធិ ការរឹតត្បិត និងលក្ខខណ្ឌទាំងឡាយ ដែលភ្ជាប់ទៅនឹងប្រភេទ ឬ សេរីនៃប័ណ្ណភាគហ៊ុនរបស់អ្នកកាន់កាប់នោះ ។

សិទ្ធិក្នុងការបោះឆ្នោតដែលបានអនុញ្ញាតក្នុងមាត្រានេះ មិនត្រូវបានលុបចោល បន្ថយ ឬ ដាក់កម្រិតដោយលក្ខន្តិកៈរបស់ក្រុមហ៊ុន ឬ តាមរបៀបណាមួយផ្សេងទៀតឡើយ ។

មាត្រា ២៣៧.-

លិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរស្តីពីមហាសន្និបាតធ្វើការកែប្រែលក្ខន្តិកៈរបស់ក្រុមហ៊ុន ត្រូវផ្ញើជូនទៅម្ចាស់ហ៊ុនដែលមានសិទ្ធិបោះឆ្នោត យ៉ាងតិច ២០(ម្ភៃ) ថ្ងៃ មុនពេលបើកមហាសន្និបាត ។ លិខិតជូនដំណឹងនេះត្រូវផ្ញើភ្ជាប់ជាមួយសេចក្តីព្រាងអត្ថបទដែលស្នើសុំធ្វើការកែប្រែលក្ខន្តិកៈ ។

មាត្រា ២៣៨.-

ការកែប្រែលក្ខន្តិកៈរបស់ក្រុមហ៊ុន អាចធ្វើបានចំពោះ :

ក- ការផ្លាស់ប្តូរនាមករណ៍ក្រុមហ៊ុន ។

ខ- ការបន្ថែម ការបន្ថយ ឬការផ្លាស់ប្តូរគោលបំណងកម្មវត្ថុអាជីវកម្ម ឬ សកម្មភាពប្រកបពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន ។

គ- ការបែងចែកសាជាថ្មី នូវចំនួនភាគហ៊ុនជាប្រភេទឡើងវិញ ដោយមានការកែប្រែលក្ខណៈដាច់ខាត និង លក្ខណៈធៀបរបស់ប្រភេទភាគហ៊ុនណាមួយ ។

ឃ- ការកែប្រែភាគលាភ នៃប្រភេទភាគហ៊ុនណាមួយ ។

ង- ការបង្កើនដើមទុនដោយបង្កើតភាគហ៊ុនប្រភេទថ្មី ដែលមានលក្ខណៈដាច់ខាត និងលក្ខណៈធៀបប្រសើរជាង ឬ ទាបជាងប្រភេទភាគហ៊ុន ដែលមានរួចហើយ ។

ច- ការបន្ថយដើមទុនចុះបញ្ជី ដោយបញ្ចុះតម្លៃចារឹកលើប័ណ្ណនៃប្រភេទភាគហ៊ុនណាមួយ ឬ ដោយបន្ថយចំនួនភាគហ៊ុនដែលបានអនុញ្ញាត ។ ដើមទុនចុះបញ្ជីមិនអាចកាត់បន្ថយឱ្យនៅតិចជាងពាក់កណ្ដាលនៃដើមទុនចុះបញ្ជីដំបូងបានឡើយដូចដែលមានចែងនៅក្នុងលក្ខន្តិកៈក្រុមហ៊ុន ។ ការបន្ថយដើមទុនមិនត្រូវហួសពី ៩០ (កៅសិប)ថ្ងៃ បន្ទាប់ពីការកែប្រែត្រូវបានកំណត់នៅក្រសួងពាណិជ្ជកម្ម ។ បើក្នុងរយៈពេលនេះមានការតវ៉ាពីម្ចាស់បំណុល ដែលគ្មានវិវាទជាមួយក្រុមហ៊ុន ម្ចាស់បំណុលនេះត្រូវបានសងប្រាក់ទាំងស្រុង មុនការបន្ថយដើមទុនដែលអាចអនុវត្តទៅបាន ។

ឆ- ការកែប្រែថិរវេលានៃអត្ថិភាពរបស់ក្រុមហ៊ុន ។

ជ- ការផ្លាស់ប្ដូរទីស្នាក់ការចុះបញ្ជី ។

ឈ- ការកែប្រែចំនួនក្លឹរ៉ុម ។

ញ- បន្ថែមបទប្បញ្ញត្តិណាមួយ ដែលច្បាប់នេះអនុញ្ញាតឱ្យដាក់បញ្ចូលទៅក្នុងលក្ខន្តិកៈរបស់ក្រុមហ៊ុន ។

មាត្រា ២៣៩.—

គ្រប់ឯកសារស្ដីពីការធ្វើការកែប្រែលក្ខន្តិកៈរបស់ក្រុមហ៊ុន ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់ពីកាលបរិច្ឆេទនៃការកែប្រែលក្ខន្តិកៈ ឬ ចំណុចកែប្រែទាំងឡាយដែលមហាសន្និបាតម្ចាស់ហ៊ុនបានសម្រេច ព្រមទាំងមានចុះហត្ថលេខារបស់ប្រធានក្រុមប្រឹក្សាភិបាល ឬ អភិបាលណាម្នាក់ដែលទទួលសិទ្ធិពីប្រធានក្រុមប្រឹក្សាភិបាល ។

ឯកសារទាំងនេះត្រូវតម្កល់ទុកនៅក្រសួងពាណិជ្ជកម្មយ៉ាងយូរ ១៥ (ដប់ប្រាំ) ថ្ងៃ ក្រោយពីមហាសន្និបាតបានសម្រេច ។

មាត្រា ២៤០.-

ពេលបានទទួលឯកសារធ្វើការកែប្រែលក្ខន្តិកៈរបស់ក្រុមហ៊ុន ក្រសួងពាណិជ្ជកម្មត្រូវចេញវិញ្ញាបនបត្របញ្ជាក់អំពីការកែប្រែលក្ខន្តិកៈនោះ ។

ការកែប្រែលក្ខន្តិកៈមានប្រសិទ្ធភាព ចាប់ពីកាលបរិច្ឆេទដែលបានបញ្ជាក់នៅក្នុងវិញ្ញាបនបត្ររបស់ក្រសួងពាណិជ្ជកម្ម។ប្រសិនបើការកែប្រែលក្ខន្តិកៈបានបញ្ជាក់អំពីកាលបរិច្ឆេទមួយទៀត កាលបរិច្ឆេទនោះមិនឱ្យលើសពី ៩០ (កៅសិប) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទកំណត់របស់វិញ្ញាបនបត្រឡើយ ។

៥.- ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា

មាត្រា ២៤១.-

ក្រុមហ៊ុនពីរ ឬ ច្រើន អាចរំលាយបញ្ចូលគ្នាជាក្រុមហ៊ុនតែមួយ ឬអាចបង្រួមចូលគ្នាជាក្រុមហ៊ុនថ្មីមួយផ្សេងទៀតបាន ។

ក្រុមហ៊ុនដែលរំលាយហៅថាក្រុមហ៊ុនដើម ។ ក្រុមហ៊ុនដែលទទួលបន្ទុកធ្វើអាជីវកម្មតទៅទៀតហៅថាក្រុមហ៊ុនថ្មី ។ ក្រុមហ៊ុនដើមនឹងត្រូវបាត់បង់នូវនីតិបុគ្គលិកលក្ខណៈ ចាប់ពីថ្ងៃដែលក្រសួងពាណិជ្ជកម្មចេញវិញ្ញាបនបត្របញ្ជាក់ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ។

មាត្រា ២៤២.-

ក្រុមប្រឹក្សាភិបាល របស់ក្រុមហ៊ុននីមួយៗ ដែលស្នើរំលាយក្រុមហ៊ុនបញ្ចូលគ្នា ត្រូវអនុម័តនូវសេចក្តីសម្រេចយល់ព្រមលើកិច្ចព្រមព្រៀងនៃការរំលាយបញ្ចូលគ្នា ។ លើកលែងតែមានចែងផ្សេងក្នុងលក្ខន្តិកៈ ការអនុម័តនេះត្រូវផ្អែកលើចំនួនភាគច្រើនដាច់ខាតនៃអភិបាលទាំងអស់ ។

មាត្រា ២៤៣.-

កិច្ចព្រមព្រៀងនៃការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវចែងពី :

ក- ចំណុចសំខាន់ៗនិងលក្ខខណ្ឌនៃការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ។

ខ- លក្ខន្តិកៈរបស់ក្រុមហ៊ុនថ្មីដែលទទួលបន្ទុកបន្តធ្វើអាជីវកម្ម ។

គ- បែបបទនៃការផ្លាស់ប្តូរភាគហ៊ុននៃប្រភេទនីមួយៗរបស់ក្រុមហ៊ុនដើមឱ្យទៅជាភាគហ៊ុន ឬ មូលបត្រផ្សេងៗរបស់ក្រុមហ៊ុនថ្មី ដែលទទួលបន្ទុកបន្តអាជីវកម្ម ។

ឃ- របាយការណ៍ស្តីពីសាច់ប្រាក់ សិទ្ធិ មូលបត្រ ឬ កម្មសិទ្ធិផ្សេងៗទៀតដែលអ្នកកាន់កាប់ភាគហ៊ុនត្រូវទទួល ក្នុងការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ប្រសិនបើភាគហ៊ុនណាមួយរបស់ក្រុមហ៊ុនដើម មិនត្រូវប្តូរទៅជាភាគហ៊ុនរបស់ក្រុមហ៊ុនថ្មី ដែលទទួលបន្ទុកបន្តអាជីវកម្មនោះទេ ។

ង- ព័ត៌មានមានផងទៀតដែលម្ចាស់ហ៊ុនក្នុងប្រភេទនីមួយៗចង់ដឹងដើម្បីជាមូលដ្ឋានធ្វើការសម្រេចចិត្តក្នុងការបោះឆ្នោតលើការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ។

ច- ព័ត៌មានលម្អិតនៃកិច្ចសម្របសម្រួលចាំបាច់ ដើម្បីធ្វើឱ្យប្រសើរឡើងនិងដើម្បីផ្តល់ដល់ការគ្រប់គ្រង ព្រមទាំងប្រតិបត្តិការនាពេលបន្ទាប់នៃក្រុមហ៊ុនថ្មីដែលទទួលបន្ទុកបន្តអាជីវកម្ម ។

មាត្រា ២៤៤.-

ក្រោយពីបានទទួលសេចក្តីសម្រេចពីក្រុមប្រឹក្សាភិបាលក្រុមហ៊ុនដើមនីមួយៗម្ចាស់ក្រុមហ៊ុនថ្មីត្រូវជូនដំណឹងទៅឱ្យម្ចាស់ហ៊ុនស្តីពីកិច្ចប្រជុំម្ចាស់ហ៊ុន ដែលមានសិទ្ធិបោះឆ្នោតនូវព័ត៌មានដូចតទៅ :

ក- នៅក្នុងរយៈពេល ៣០(សាមសិប)ថ្ងៃ ក្រោយកិច្ចព្រមព្រៀងនេះក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនដើមនីមួយៗត្រូវធ្វើមហាសន្និបាតម្ចាស់ហ៊ុន ដើម្បីបោះឆ្នោតសម្រេចលើកិច្ចព្រមព្រៀងស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ។

ខ- លិខិតជូនដំណឹងត្រូវភ្ជាប់ជាមួយនឹងច្បាប់ចម្លងនៃកិច្ចព្រមព្រៀងស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ។

គ- ក្រុមហ៊ុនដើមនីមួយៗត្រូវផ្តល់លិខិតជូនដំណឹងស្តីពីកិច្ចប្រជុំម្ចាស់ហ៊ុនយ៉ាងតិច ២០(ម្ភៃ)ថ្ងៃមុន ។

មាត្រា ២៤៥.-

ការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវមានការយល់ព្រមដោយសេចក្តីសម្រេចពិសេសរបស់ម្ចាស់ហ៊ុនពីរភាគបី (២/៣) នៃក្រុមហ៊ុនដើមនីមួយៗ ។

មាត្រា ២៤៦.-

ទោះបីលក្ខន្តិកៈរបស់ក្រុមហ៊ុនមិនអនុញ្ញាតឱ្យប្រភេទភាគហ៊ុនណាមួយមានសិទ្ធិជាទូទៅ ក្នុងការបោះឆ្នោតក៏ដោយ ក៏ប្រភេទភាគហ៊ុននោះនឹងនៅតែមានសិទ្ធិដោយឡែក ក្នុងការបោះឆ្នោតទៅតាមប្រភេទភាគហ៊ុនរបស់ខ្លួន ដើម្បីសម្រេចលើការរំលាយក្រុមហ៊ុនបញ្ចូលគ្នាដែលអាចនឹងកែប្រែដោយផ្ទាល់ និងដោយប្រយោលនូវសិទ្ធិ ឯកសិទ្ធិ ការរឹតត្បិតនិងលក្ខខណ្ឌនៃប្រភេទ ឬ សេរីនៃភាគហ៊ុនផ្សេងៗ ។

អំណាចបោះឆ្នោតដែលបង្កើតឡើងក្នុងមាត្រានេះមិនអាចបដិសេធឬកែប្រែដោយលក្ខន្តិកៈរបស់ក្រុមហ៊ុន ឬតាមរបៀបណាផ្សេងទៀតបានឡើយ ។

មាត្រា ២៤៧.-

អភិបាលរបស់ក្រុមហ៊ុនថ្មី ដែលទទួលធ្វើអាជីវកម្មបន្ត ត្រូវតម្កល់ឯកសារទុកនៅក្រសួងពាណិជ្ជកម្ម ដែលមានជាអាទិ៍ :

ក- កិច្ចព្រមព្រៀងស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ។

ខ- សេចក្តីសម្រេចយល់ព្រមលើកិច្ចព្រមព្រៀង ស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នានៃអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល និងនៃមហាសន្និបាតម្ចាស់ហ៊ុនរបស់ក្រុមហ៊ុនដើមនីមួយៗ ។

គ- លក្ខន្តិកៈរបស់ក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្ត ។

ឃ- សេចក្តីប្រកាសរបស់អភិបាលឬអ្នកគ្រប់គ្រងនៃក្រុមហ៊ុនដើមនីមួយៗ ដែលធ្វើឡើងតាមការទាមទារពីមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ។ សេចក្តីប្រកាសនោះត្រូវមានមូលហេតុសមរម្យដូចតទៅ :

១- ក្រុមហ៊ុនដើមនិងក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្តនីមួយៗគឺមានលទ្ធភាពសងបំណុលរបស់ខ្លួន តាមពេលវេលាដែលត្រូវសង ។

២- ធនធានសរុបរបស់ក្រុមហ៊ុនថ្មី ដែលទទួលធ្វើអាជីវកម្មបន្ត មិនត្រូវតិចជាងចំនួនសរុបនៃបំណុលដែលខ្លួនជំពាក់ និងដើមទុនចុះបញ្ជីនៃក្រុមហ៊ុនដើម ។

៣- គ្មានម្ចាស់បំណុលណាមួយទទួលការខូចខាតដោយសារការរំលាយក្រុមហ៊ុនបញ្ចូលគ្នានេះទេ ។

៤- លិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរ ត្រូវបានប្រគល់ឱ្យម្ចាស់បំណុលទាំងអស់របស់ក្រុមហ៊ុនដើម ហើយគ្មានម្ចាស់បំណុលណាមួយធ្វើការជំទាស់ដែលមានមូលហេតុស្របទៅលើការរំលាយបញ្ចូលគ្នានោះទេ ។

មាត្រា ២៥៨.-

នៅពេលទទួលលក្ខន្តិកៈស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ក្រសួងពាណិជ្ជកម្មត្រូវចេញវិញ្ញាបនបត្របញ្ជាក់ពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ចាប់ពីកាលបរិច្ឆេទដែលមានចុះនៅលើវិញ្ញាបនបត្រនេះ :

ក- ការរំលាយបញ្ចូលគ្នារបស់ក្រុមហ៊ុនដើម និងការបន្តជាក្រុមហ៊ុនតែមួយរបស់គេ ត្រូវចូលជាធរមាន ។

ខ- កម្មសិទ្ធិរបស់ក្រុមហ៊ុនដើមនីមួយៗ ត្រូវបានជាកម្មសិទ្ធិក្រុមហ៊ុនថ្មីដែលបន្តធ្វើអាជីវកម្ម ។

គ- ក្រុមហ៊ុនថ្មីដែលបន្តធ្វើអាជីវកម្មត្រូវទទួលខុសត្រូវចំពោះកាតព្វកិច្ចរបស់ក្រុមហ៊ុនដើមនីមួយៗ ។

ឃ- កិច្ចការរដ្ឋប្បវេណី ព្រហ្មទណ្ឌ ឬរដ្ឋបាលណាមួយ ដែលពាក់ព័ន្ធដល់ក្រុមហ៊ុនដើមណាមួយនោះ នៅតែមានជាធរមានក្នុងទំនាក់ទំនងជាមួយក្រុមហ៊ុនថ្មីដែលបន្តធ្វើអាជីវកម្ម ។

ង- លក្ខន្តិកៈស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវចាត់ទុកជាលក្ខន្តិកៈសម្រាប់ការធ្វើអាជីវកម្មរបស់ក្រុមហ៊ុនថ្មី ហើយវិញ្ញាបនបត្របញ្ជាក់ការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ត្រូវចាត់ទុកជាវិញ្ញាបនបត្របញ្ជាក់ពីការធ្វើអាជីវកម្មសម្រាប់ក្រុមហ៊ុនថ្មីដែលបន្តធ្វើអាជីវកម្ម ។

មាត្រា ២៤៩.-

ក្នុងការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ម្ចាស់ហ៊ុនមួយចំនួននៃក្រុមហ៊ុនដើម មានសិទ្ធិទាមទារឱ្យមានការវាយតម្លៃ លើតម្លៃភាគហ៊ុនរបស់ខ្លួននៅក្នុងក្រុមហ៊ុនដើម ។ ប៉ុន្តែដើម្បីទទួលបានសិទ្ធិធ្វើការវាយតម្លៃ ម្ចាស់ហ៊ុនទាំងនោះត្រូវបំពេញលក្ខខណ្ឌដូចតទៅ :

ក- មុនពេលម្ចាស់ហ៊ុនបានបោះឆ្នោតធ្វើការរំលាយក្រុមហ៊ុនបញ្ចូលគ្នា ម្ចាស់ហ៊ុនត្រូវកាន់កាប់ភាគហ៊ុននៅក្នុងក្រុមហ៊ុនដើមណាមួយ ។

ខ- នៅក្នុងពេលបោះឆ្នោត ម្ចាស់ហ៊ុននោះមិនបានបោះឆ្នោតគាំទ្រការរំលាយក្រុមហ៊ុនបញ្ចូលគ្នាទេ ។

គ- ម្ចាស់ហ៊ុននោះត្រូវធ្វើការទាមទារជាលាយលក្ខណ៍អក្សរចំពោះក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្ត ក្រោយពីលក្ខន្តិកៈស្តីពីការរំលាយក្រុមហ៊ុនបញ្ចូលគ្នាត្រូវបានតម្កល់ទុកនៅក្រសួងពាណិជ្ជកម្ម ។

ឃ- នៅពេលដែលធ្វើការទាមទារវាយតម្លៃ ម្ចាស់ហ៊ុននោះត្រូវប្រគល់ប័ណ្ណភាគហ៊ុនរបស់ខ្លួន ទៅឱ្យក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្ត ។

មាត្រា ២៥០.-

នៅពេលមានការទាមទារវាយតម្លៃលើតម្លៃភាគហ៊ុន ក្រុមហ៊ុនថ្មីដែលទទួលធ្វើអាជីវកម្មបន្តនិងម្ចាស់ហ៊ុនដែលធ្វើការទាមទារនេះ ត្រូវចរចាគ្នាដើម្បីសម្រុះសម្រួល

វកតម្លៃសមរម្យមួយក្នុងរយៈពេល ៩០(កៅសិប)ថ្ងៃ ដើម្បីឱ្យមានការព្រមព្រៀងលើតម្លៃសមរម្យមួយសម្រាប់ភាគហ៊ុនទាំងនោះ ។

តម្លៃសមរម្យត្រូវកំណត់តាមការពិនិត្យគ្រប់កត្តាដែលពាក់ព័ន្ធទាំងអស់ លើកលែងតែតម្លៃណាមួយដែលមានកំណត់រួចហើយ នៅក្នុងកិច្ចសន្យាវិលាយក្រុមហ៊ុនបញ្ចូលគ្នា ។

លក្ខន្តិកៈរបស់ក្រុមហ៊ុនដើមណាមួយ ឬកិច្ចព្រមព្រៀងនៃការវិលាយក្រុមហ៊ុនបញ្ចូលគ្នាអាចចែងថា គ្រប់វិវាទក្នុងការវាយតម្លៃ នឹងត្រូវសម្រេចដោយមជ្ឈត្តកម្ម ។ មុននឹងមជ្ឈត្តករចេញសេចក្ដីសម្រេចចុងក្រោយ ម្ចាស់ហ៊ុនអាចដកបណ្ដឹងទាមទាររបស់ខ្លួន ក្នុងការវាយតម្លៃនៅពេលណាមួយក៏បាន ។ ក្នុងករណីនេះ ម្ចាស់ហ៊ុននោះត្រូវមានសិទ្ធិទទួលពីក្រុមហ៊ុនថ្មី ដែលទទួលធ្វើអាជីវកម្មបន្តនូវតម្លៃសមមូល ដែលក្រុមហ៊ុនបានកំណត់ពីមុន ។

ប្រសិនបើមិនអាចព្រមព្រៀងគ្នាលើតម្លៃសមរម្យណាមួយបានទេ ភាគីទាំងពីរត្រូវប្រគល់ជូនតុលាការដែលមានសមត្ថកិច្ចសម្រេចពីតម្លៃសមរម្យមួយ ហើយម្ចាស់ហ៊ុនដែលទាមទារត្រូវទទួលទៅតាមចំនួននោះ ។

ង- ការរំលាយក្រុមហ៊ុន និង ការជម្រះបញ្ជី

មាត្រា ២៥១.-

ក្រុមហ៊ុនដែលគ្មានចេញប័ណ្ណភាគហ៊ុនណាមួយ អាចរំលាយនៅពេលណាក៏បាន តាមរយៈសេចក្ដីសម្រេចរបស់អភិបាលទាំងអស់ ។

ក្រុមហ៊ុនគ្មានទ្រព្យសម្បត្តិនិងគ្មានបំណុល អាចធ្វើការរំលាយបាន តាមរយៈសេចក្ដីសម្រេចចិត្តពិសេសរបស់ម្ចាស់ហ៊ុន ឬប្រសិនបើក្រុមហ៊ុនមានចេញប័ណ្ណភាគហ៊ុនច្រើនជាងមួយប្រភេទនោះ ការរំលាយត្រូវធ្វើតាមរយៈសេចក្ដីសម្រេចពិសេសរបស់អ្នកកាន់កាប់ភាគហ៊ុននៃប្រភេទនីមួយៗ ទោះបីម្ចាស់ហ៊ុននោះមានសិទ្ធិ ឬគ្មានសិទ្ធិបោះឆ្នោតក៏ដោយ ។

ក្រុមហ៊ុនត្រូវបញ្ជូនសេចក្ដីសម្រេចរំលាយក្រុមហ៊ុនទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៅក្រសួងពាណិជ្ជកម្ម ។

នៅពេលបានទទួលសេចក្ដីសម្រេចរំលាយក្រុមហ៊ុន មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ត្រូវចេញវិញ្ញាបនបត្ររំលាយក្រុមហ៊ុនឱ្យដល់ក្រុមហ៊ុន ។

ក្រុមហ៊ុនត្រូវបានចាត់ទុកថាលែងមានអត្ថិភាពតទៅទៀត ចាប់ពីថ្ងៃចេញវិញ្ញាបនបត្ររំលាយក្រុមហ៊ុន ។

មាត្រា ២៥២.-

អភិបាលឬម្ចាស់ភាគហ៊ុនម្នាក់ដែលមានសិទ្ធិបោះឆ្នោត នៅពេលមហាសន្និបាតម្ចាស់ហ៊ុនអាចស្នើឱ្យជម្រះបញ្ជីនិងរំលាយក្រុមហ៊ុនដោយស្ម័គ្រចិត្ត ។

លិខិតជូនដំណឹងស្ដីពីការប្រជុំរបស់ម្ចាស់ហ៊ុនក្នុងបំណងជម្រះបញ្ជី ឬ រំលាយក្រុមហ៊ុនដែលស្នើឡើង ត្រូវចែងពីលក្ខខណ្ឌសម្រាប់ការជម្រះបញ្ជីនិងការរំលាយក្រុមហ៊ុននោះ ។

ក្រុមហ៊ុនដែលមានទ្រព្យសម្បត្តិ និង/ឬ មានបំណុល អាចធ្វើការរំលាយបានតាមរយៈសេចក្ដីសម្រេចចិត្តពិសេសមួយរបស់អ្នកកាន់ភាគហ៊ុននៃប្រភេទនីមួយៗ ។ ក្នុងករណីដែលក្រុមហ៊ុនមានចេញប័ណ្ណភាគហ៊ុនច្រើនជាងមួយប្រភេទ ត្រូវធ្វើការជម្រះបញ្ជី និងរំលាយតាមរយៈសេចក្ដីសម្រេចពិសេសរបស់អ្នកកាន់ភាគហ៊ុននៃប្រភេទនីមួយៗ ដោយមិនគិតថាម្ចាស់ហ៊ុននោះមានសិទ្ធិ ឬគ្មានសិទ្ធិបោះឆ្នោតទេ ប្រសិនបើ :

១- ម្ចាស់ហ៊ុនអនុញ្ញាតឱ្យអភិបាលធ្វើការបែងចែកទ្រព្យសម្បត្តិ និងទូទាត់បំណុលរបស់ក្រុមហ៊ុន តាមសេចក្ដីសម្រេចពិសេសឬ សេចក្ដីសម្រេចសាមញ្ញ ។

២- ក្រុមហ៊ុនបានធ្វើការបែងចែកទ្រព្យសម្បត្តិ និងទូទាត់បំណុលមុនពេលបញ្ជូនលក្ខន្តិកៈនៃការរំលាយក្រុមហ៊ុន ទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ។

108/...

មាត្រា ២៥៣.-

ក្រោយពីមានការយល់ព្រមលើសេចក្តីសម្រេចជម្រះបញ្ជី និងរំលាយក្រុមហ៊ុន ក្រុមហ៊ុនត្រូវធ្វើសេចក្តីប្រកាសពីបំណងរំលាយជាទម្រង់លិខិតទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ។

នៅពេលទទួលសេចក្តីប្រកាសពីបំណងរំលាយ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ត្រូវចេញវិញ្ញាបនបត្របញ្ជាក់ពីបំណងរំលាយក្រុមហ៊ុននោះ ។

នៅពេលដែលចេញវិញ្ញាបនបត្របញ្ជាក់បំណងនៃការរំលាយក្រុមហ៊ុនក្រុមហ៊ុនត្រូវបញ្ឈប់ការធ្វើអាជីវកម្ម លើកលែងតែចំពោះការពន្យារចាំបាច់សម្រាប់ការជម្រះបញ្ជី ប៉ុន្តែនីតិបុគ្គលិកលក្ខណៈរបស់ក្រុមហ៊ុន នៅតែមានសុពលភាពរហូតដល់ក្រសួងពាណិជ្ជកម្មចេញវិញ្ញាបនបត្របញ្ជាក់ការរំលាយជាស្ថាពរ ។

មាត្រា ២៥៤.-

ក្រោយពេលចេញវិញ្ញាបនបត្របញ្ជាក់ពីបំណងនៃការរំលាយក្រុមហ៊ុន ដោយមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ក្រុមហ៊ុនត្រូវ :

ក- ផ្ញើលិខិតជូនដំណឹងស្តីពីបំណងរំលាយជាបន្ទាន់ទៅឱ្យម្ចាស់បំណុលរបស់ក្រុមហ៊ុន ។

ខ- ចុះផ្សាយលិខិតជូនដំណឹងស្តីពីបំណងនៃការរំលាយជាបន្ទាន់ សម្រាប់រយៈពេល ២ (ពីរ) សប្តាហ៍ជាប់ៗគ្នានៅក្នុងសារព័ត៌មានដែលបោះផ្សាយ ឬចែកចាយក្នុងកន្លែងដែលក្រុមហ៊ុនមានស្នាក់ការចុះបញ្ជីពិតប្រាកដ ឬបោះពុម្ពផ្សាយផងទៃទៀតដូចបានកំណត់ក្នុងបទបញ្ជារបស់ក្រសួងពាណិជ្ជកម្ម ។

មាត្រា ២៥៥.-

ក្រោយពីការចេញវិញ្ញាបនបត្របញ្ជាក់ពីបំណងនៃការរំលាយ ក្រុមហ៊ុនត្រូវ :

-ប្រមូលទ្រព្យសម្បត្តិ

-រក្សាទុកទ្រព្យសម្បត្តិជាវត្ថុដែលមិនអាចធ្វើការបែងចែកទៅឱ្យម្ចាស់ហ៊ុន

-បំពេញកាតព្វកិច្ចទាំងឡាយ

-ធ្វើសកម្មភាពផ្សេងទៀត ដែលតម្រូវសម្រាប់ធ្វើការជម្រះបញ្ជី ។

ក្រោយពីបានទទួលលិខិតជូនដំណឹងពីការរំលាយ និងការសងប្រាក់បានគ្រប់គ្រាន់ ឬការបញ្ឈប់សកម្មភាពទាំងអស់របស់ក្រុមហ៊ុន ក្រុមហ៊ុនត្រូវបែងចែកទ្រព្យសម្បត្តិដែលនៅសល់ ទាំងកម្មសិទ្ធិជាសាច់ប្រាក់ ឬ ជាវត្ថុទៅឱ្យម្ចាស់ហ៊ុន ដែលមានសិទ្ធិទទួលទ្រព្យសម្បត្តិនោះ ។

មាត្រា ២៥៦.-

នៅគ្រប់ពេលក្នុងអំឡុងពេលនៃការជម្រះបញ្ជីរបស់ក្រុមហ៊ុន មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ឬជនដែលមានការពាក់ព័ន្ធផលប្រយោជន៍អាចស្នើទៅតុលាការ ដើម្បីឱ្យការជម្រះបញ្ជីក្រោមការត្រួតពិនិត្យរបស់តុលាការ ។

អ្នកដាក់ពាក្យសុំត្រូវផ្តល់ឱ្យក្រសួងពាណិជ្ជកម្មនូវលិខិតជូនដំណឹងស្តីពីការអនុវត្ត ហើយមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម មានសិទ្ធិបង្ហាញតុលាការដោយផ្ទាល់ ឬតាមរយៈតំណាង ។

មាត្រា ២៥៧.-

នៅពេលជម្រះបញ្ជីត្រូវបានបញ្ចប់ ក្រុមហ៊ុនត្រូវរៀបចំសេចក្តីសម្រេចស្តីពីការរំលាយក្រុមហ៊ុន ។

សេចក្តីសម្រេចស្តីពីការរំលាយត្រូវផ្ញើទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ។

នៅពេលទទួលសេចក្តីសម្រេចស្តីពីការរំលាយក្រុមហ៊ុន មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ត្រូវចេញវិញ្ញាបនបត្របញ្ជាក់ការរំលាយក្រុមហ៊ុន ។

ក្រុមហ៊ុនត្រូវបញ្ឈប់អត្ថិភាពរបស់ខ្លួន ចាប់ពីថ្ងៃដែលមានចុះនៅក្នុងវិញ្ញាបនបត្របញ្ជាក់ការរំលាយក្រុមហ៊ុន ។

មាត្រា ២៥៨.-

បទប្បញ្ញត្តិស្តីពីការរំលាយ និងការជម្រះបញ្ជីខាងលើ មិនត្រូវអនុវត្តចំពោះក្រុមហ៊ុនដែលដាក់ពាក្យសុំក្ស័យធនទៅតុលាការឡើយ ។

ខ- មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម

មាត្រា ២៥៩.-

ក្រសួងពាណិជ្ជកម្មត្រូវតែងតាំងមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មម្នាក់ ឬច្រើននាក់តាមការចាំបាច់ ដើម្បីឱ្យបំពេញតួនាទីស្របតាមច្បាប់នេះ ។

មាត្រា ២៦០.-

ក្រសួងពាណិជ្ជកម្មចេញវិញ្ញាបនបត្រ ឬ បញ្ជាក់អំពីសកម្មភាពណាមួយរបស់ក្រុមហ៊ុន ។ វិញ្ញាបនបត្រនេះត្រូវចុះហត្ថលេខាដោយមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ។

មាត្រា ២៦១.-

លិខិតជូនដំណឹង ឬឯកសារផ្សេងៗ ដែលពាក់ព័ន្ធដល់ការគ្រប់គ្រងក្រុមហ៊ុនត្រូវផ្ញើទៅមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ។ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មអាចទទួលយកឯកសារថតចម្លងផ្សេងៗទាំងនោះបាន ។

មាត្រា ២៦២.-

មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម អាចទាមទារឱ្យក្រុមហ៊ុនផ្ញើឯកសារបញ្ជាក់ពីភាពត្រឹមត្រូវ ឬ ហេតុការណ៍ពិត ដែលមានចែងនៅក្នុងឯកសារស្របតាមច្បាប់នេះ ។

មាត្រា ២៦៣.-

ក្រសួងពាណិជ្ជកម្មអាចធ្វើសេចក្ដីណែនាំដែលមានចំណុចដូចខាងក្រោម :

ក- ការតម្រូវឱ្យរៀបរាប់ហេតុផលសំខាន់ៗដោយលម្អិត តាមការអនុញ្ញាតនៃច្បាប់នេះ ។

ខ- ការតម្រូវឱ្យមានការបង់ថ្លៃឈ្នួលចំពោះការតម្កល់ទុក ការត្រួតពិនិត្យ ឬ ការថតចម្លងឯកសារណាមួយ ឬ ចំពោះសកម្មភាពណាមួយ ។

គ- ការរៀបរាប់ពីមាតិកាតាមប្រព័ន្ធអេឡិចត្រូនិច ឬ ទម្រង់បែបបទនៃលិខិតជូនដំណឹងដទៃទៀត ព្រមទាំងឯកសារចាំបាច់ដែលត្រូវផ្ញើជូន ឬ ចេញដោយក្រសួងពាណិជ្ជកម្ម ។

ឃ- ការប្រតិបត្តិដែលទាក់ទងដល់ការបញ្ជូន ឬ ការចេញនូវលិខិតជូនដំណឹងនិងឯកសារផ្សេងៗ ។

ង- ការរៀបរាប់ពីវិធាននានា ដែលទាក់ទងដល់ការលើកលែងមួយចំនួនដែលអនុញ្ញាតដោយច្បាប់នេះ ។

មាត្រា ២៦៤.-

លក្ខន្តិកៈ និងផែនការរំលាយក្រុមហ៊ុន ត្រូវផ្ញើទៅឱ្យក្រសួងពាណិជ្ជកម្ម ត្រូវមានហត្ថលេខាដោយអភិបាលម្នាក់ ឬ អ្នកគ្រប់គ្រងម្នាក់របស់ក្រុមហ៊ុន ឬ ដោយស្ថាបនិកម្នាក់ក្នុងករណីដែលតម្រូវដោយលក្ខន្តិកៈ ។

ក្រោយពីបានទទួលនូវឯកសារ ឬ ផែនការតាមទម្រង់កំណត់ហើយនោះ មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មត្រូវ :

104/105

១- កត់ត្រាទុកកាលបរិច្ឆេទនៃការតម្កល់ទុក ។

២- ចេញវិញ្ញាបនបត្រ ។

៣- តម្កល់ទុកនូវវិញ្ញាបនបត្រនិងឯកសារ ឬ សេចក្ដីប្រកាសរួបថត ព័ត៌មាន អេឡិចត្រូនិច ឬរាល់ការថតចម្លងឡើងវិញនៃវិញ្ញាបនបត្រនិងឯកសារ ឬ សេចក្ដីប្រកាស ។

៤- ផ្ញើវិញ្ញាបនបត្រនិងឯកសារ ឬសេចក្ដីប្រកាសរួបថតព័ត៌មាន អេឡិចត្រូនិច ឬរាល់ការថតចម្លងឡើងវិញនៃវិញ្ញាបនបត្រនិងឯកសារ ឬ សេចក្ដីប្រកាសទៅឱ្យក្រុមហ៊ុន ឬ តំណាងរបស់ក្រុមហ៊ុន ។

៥- ចុះផ្សាយនូវលិខិតជូនដំណឹងនៃការចេញវិញ្ញាបនបត្រនៅក្នុងព្រឹត្តិបត្ររបស់ក្រសួងពាណិជ្ជកម្ម ។

មាត្រា ២៦៥.-

វិញ្ញាបនបត្រដែលបានចេញដោយក្រសួងពាណិជ្ជកម្ម អាចចុះកាលបរិច្ឆេទនៅថ្ងៃដែលទទួលឯកសារ ឬ ផែនការ ឬ ដីការបស់តុលាការដែលបញ្ជាឱ្យចេញវិញ្ញាបនបត្រ ឬ នៅថ្ងៃបន្ទាប់ទៀត ដែលបានបញ្ជាក់ដោយតុលាការ ឬ បុគ្គល ដែលបានចុះហត្ថលេខាលើឯកសារ ឬ ផែនការនោះ ។

មាត្រា ២៦៦.-

មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម អាចផ្ដល់ឱ្យបុគ្គលណាម្នាក់នូវវិញ្ញាបនបត្រ និងឯកសារចាំបាច់ដែលក្រុមហ៊ុនបានផ្ញើមកឱ្យក្រសួងពាណិជ្ជកម្មស្របតាមច្បាប់នេះ ។

មាត្រា ២៦៧.-

ប្រសិនបើវិញ្ញាបនបត្រដែលចេញឱ្យក្រុមហ៊ុន ដោយមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម មានកំហុសឆ្គងដោយអចេតនាណាមួយនោះ អភិបាល ឬ ម្ចាស់ហ៊ុនត្រូវបញ្ជូនទៅឱ្យមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម

ដើម្បីកែតម្រូវឡើងវិញតាមច្បាប់នេះ ។ បើមានហេតុផលត្រឹមត្រូវ ក្រសួងពាណិជ្ជកម្ម អាចបដិសេធវិញ្ញាបនបត្រដែលខុស និងចេញវិញ្ញាបនបត្រដែលត្រឹមត្រូវជំនួសវិញ ។

វិញ្ញាបនបត្រត្រឹមត្រូវថ្មីនេះ ត្រូវមានកាលបរិច្ឆេទតែមួយ ដូចវិញ្ញាបនបត្រចាស់ដែរ ។

ប្រសិនបើវិញ្ញាបនបត្រត្រឹមត្រូវថ្មីនេះ មានការកែប្រែលក្ខខណ្ឌផ្សេងពីវិញ្ញាបនបត្រដើមនោះមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ត្រូវផ្តល់លិខិតជូនដំណឹងជាបន្ទាន់ចំពោះការកែប្រែនោះ នៅក្នុងព្រឹត្តិបត្ររបស់ក្រសួងពាណិជ្ជកម្ម ។

មាត្រា ២៦៨.-

បុគ្គលណាមួយដែលបានបង់ថ្លៃឈ្នួលរួចហើយ បុគ្គលនោះមានសិទ្ធិត្រួតពិនិត្យឯកសារនានា ដែលបានផ្ញើទៅក្រសួងពាណិជ្ជកម្មនៅគ្រប់ម៉ោងធ្វើការ ហើយអាចធ្វើការថតចម្លង ឬ ដកស្រង់របាយការណ៍ផ្សេងៗបាន ។ ការផ្តល់ឯកសារ ឬ ថតចម្លងឯកសារដល់បុគ្គលណាម្នាក់ មិនត្រូវបានអនុវត្តចំពោះរបាយការណ៍ស៊ើបអង្កេតរបស់តុលាការទេ ។

មន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម អាចផ្តល់ឱ្យបុគ្គលណាម្នាក់នូវច្បាប់ចម្លង ឬ ច្បាប់ចម្លងដែលមានការបញ្ជាក់របស់ឯកសារនានា ស្របតាមលក្ខខណ្ឌនៃមាត្រានេះ ។

នៅពេលដែលឯកសារត្រូវបានរក្សាទុកដោយក្រសួងពាណិជ្ជកម្ម ហើយឯកសារនោះមានទម្រង់ជាលាយលក្ខណ៍អក្សរ ត្រូវមានលក្ខខណ្ឌដូចតទៅនេះ :

ក- ក្រសួងពាណិជ្ជកម្មត្រូវផ្តល់ឯកសារចម្លងដែលតម្រូវឱ្យផ្តល់ ស្របតាមមាត្រានេះ ជាទម្រង់ឯកសារដែលអាចអានបាន ។

ខ- របាយការណ៍ដែលស្រង់ចេញពីឯកសារតម្កល់ទាំងនេះ ប្រសិនបើមានការបញ្ជាក់ពីមន្ត្រីទទួលបន្ទុកគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្មជាភស្តុតាងដែលមានតម្លៃដូចឯកសារដើមដែរ ។

មាត្រា ២៦៩.–

ក្រសួងពាណិជ្ជកម្មមិនមានកាតព្វកិច្ចផ្តល់ឯកសារនានា ក្រៅពីវិញ្ញាបនបត្រ និង ផែនការរំលាយក្រុមហ៊ុនដែលបានភ្ជាប់មកជាមួយ ក្រោយរយៈពេល ១០ (ដប់)ឆ្នាំ គិតចាប់ពីថ្ងៃដែលបានទទួល ។

ជំពូកទី ៤
ក្រុមហ៊ុនពាណិជ្ជកម្មបរទេស
បទប្បញ្ញត្តិទូទៅ

មាត្រា ២៧០.–

ក្រុមហ៊ុនពាណិជ្ជកម្មបរទេសគឺជាក្រុមហ៊ុនដែលបង្កើតឡើងក្រោមច្បាប់នៃប្រទេសដទៃ ហើយបានមកបោះទីតាំងធ្វើពាណិជ្ជកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២៧១.–

ក្រុមហ៊ុនពាណិជ្ជកម្មបរទេស អាចមកបោះទីតាំងធ្វើពាណិជ្ជកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជាបាន តាមបែបបទផ្សេងៗដូចតទៅ :

- ក- ការិយាល័យតំណាងពាណិជ្ជកម្ម ឬ ការិយាល័យទំនាក់ទំនងពាណិជ្ជកម្ម ។
- ខ- សាខាក្រុមហ៊ុនពាណិជ្ជកម្ម ។
- គ- បុត្រសម្ព័ន្ធ ។

ការិយាល័យតំណាងពាណិជ្ជកម្ម និងសាខាក្រុមហ៊ុនគឺជាភ្នាក់ងាររបស់ក្រុមហ៊ុនដើម ហើយពុំមាននីតិបុគ្គលិកលក្ខណៈដាច់ដោយឡែកពីក្រុមហ៊ុនដើមឡើយ ។

មាត្រា ២៧២.–

ក្រុមហ៊ុនពាណិជ្ជកម្មបរទេស ត្រូវចាត់ទុកថាកំពុងធ្វើសកម្មភាពពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ប្រសិនបើក្រុមហ៊ុនពាណិជ្ជកម្មបរទេសនោះ បានធ្វើសកម្មភាពនានាដូចខាងក្រោម :

ក- ជួលការិយាល័យ ជួលកន្លែងផលិត ឬ កែច្នៃ ឬ សេវាដែលមានរយៈពេលចាប់ពី ០១(មួយ)ខែឡើងទៅ ។

ខ- ជួលបុគ្គលិកសម្រាប់បម្រើការងារឱ្យក្រុមហ៊ុន ដែលមានរយៈពេលចាប់ពីមួយខែឡើងទៅ ។

គ- ធ្វើសកម្មភាពដទៃណាមួយទៀត ដែលច្បាប់នៃព្រះរាជាណាចក្រកម្ពុជាអនុញ្ញាតចំពោះរូបវន្តបុគ្គល ឬ នីតិបុគ្គលបរទេស ។

មាត្រា ២៧៣.-

គ្រប់ក្រុមហ៊ុនបរទេសនានាធ្វើពាណិជ្ជកិច្ចនៅក្នុងព្រះរាជាណាចក្រកម្ពុជា ទោះជាក្នុងរូបភាពណាមួយក៏ដោយ ក៏ត្រូវស្ថិតនៅក្រោមច្បាប់ និងយុត្តាធិការរបស់តុលាការនៃព្រះរាជាណាចក្រកម្ពុជា ។

ក្រុមហ៊ុនបរទេសទាំងនោះត្រូវបំពេញទម្រង់បែបបទនៃការចុះបញ្ជីពាណិជ្ជកម្មស្របតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ។

គ- ការិយាល័យតំណាងពាណិជ្ជកម្ម

មាត្រា ២៧៤.-

ការិយាល័យតំណាងពាណិជ្ជកម្ម ឬ ការិយាល័យទំនាក់ទំនងពាណិជ្ជកម្មអាចធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជាបាន ជាអាទិ៍ :

ក- ទំនាក់ទំនងផ្សេងៗជាមួយអតិថិជននានា ក្នុងគោលដៅធ្វើឱ្យអតិថិជនទាំងនោះបានស្គាល់ក្រុមហ៊ុនដើមរបស់ខ្លួន ។

ខ- ស្រាវជ្រាវព័ត៌មានពាណិជ្ជកម្ម និងផ្តល់ព័ត៌មានទាំងនេះជូនទៅក្រុមហ៊ុនដើមនៅបរទេស ។

គ- ស្រាវជ្រាវទីផ្សារនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ឃ- ឃោសនាផលិតផល តាំងពិព័រណ៍ពាណិជ្ជកម្ម បង្ហាញផលិតផល នៅការិយាល័យរបស់ខ្លួន ឬនៅកន្លែងតាំងពិព័រណ៍ផ្សេងទៀត នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ង- ទិញ និងរក្សាទុកទំនិញមួយចំនួន សម្រាប់គោលដៅបម្រើឱ្យការតាំងពិព័រណ៍ពាណិជ្ជកម្ម ។

ច- ជួលទីតាំងការិយាល័យ និងជួលបុគ្គលិកក្នុងស្រុក ដើម្បីបម្រើការងារ ។

ឆ- ចុះកិច្ចសន្យាពាណិជ្ជកម្មជាមួយអតិថិជនក្នុងស្រុកក្នុងនាមក្រុមហ៊ុនដើម ។

ប៉ុន្តែការិយាល័យតំណាងពាណិជ្ជកម្ម ឬ ការិយាល័យទំនាក់ទំនងពាណិជ្ជកម្ម មិនអាចធ្វើសកម្មភាពទិញ លក់និងធ្វើសេវាជាអាជីពប្រចាំ ឬសកម្មភាពពាក់ព័ន្ធនឹងប្រតិបត្តិការផលិតកែច្នៃ និងសាងសង់ នៅក្នុងព្រះរាជាណាចក្រកម្ពុជាបានឡើយ ។

មាត្រា ២៧៥.-

ការិយាល័យតំណាងពាណិជ្ជកម្ម ឬការិយាល័យទំនាក់ទំនងពាណិជ្ជកម្ម ត្រូវគ្រប់គ្រងដោយនាយកគ្រប់គ្រងមួយរូប ឬច្រើនរូបដែលត្រូវតែងតាំងនិងដកហូតដោយក្រុមហ៊ុនដើម ។

មាត្រា ២៧៦.-

នាមករណ៍របស់ការិយាល័យតំណាងពាណិជ្ជកម្ម ឬ ការិយាល័យទំនាក់ទំនងពាណិជ្ជកម្ម ជានាមករណ៍របស់ក្រុមហ៊ុនដើមនៅឯបរទេស ។ នៅខាងលើឬ នៅពីមុខនាមករណ៍នេះត្រូវសរសេរដាក់ថា ការិយាល័យតំណាងពាណិជ្ជកម្ម ឬ ការិយាល័យទំនាក់ទំនងពាណិជ្ជកម្ម ។

មាត្រា ២៧៧.-

ការិយាល័យតំណាងពាណិជ្ជកម្ម ឬការិយាល័យទំនាក់ទំនងពាណិជ្ជកម្មអាចត្រូវរំលាយបានដោយសេចក្ដីសម្រេចរបស់ក្រុមហ៊ុនដើម ។

ខ- សាខាក្រុមហ៊ុន

មាត្រា ២៧៨.-

សាខាក្រុមហ៊ុនអាចធ្វើសកម្មភាពបានដូចការិយាល័យតំណាងពាណិជ្ជកម្មដែរ ។

លើសពីនេះទៀត សាខាក្រុមហ៊ុនអាចទិញនិងលក់ជាប្រចាំបាននូវទំនិញ និងសេវាកម្ម ព្រមទាំងធ្វើសកម្មភាពដែលទាក់ទងទៅនឹងការផលិត ការកែច្នៃ និងការស្ថាបនាដូចសហគ្រាសក្នុងស្រុកដែរ លើកលែងតែសកម្មភាពណាដែលច្បាប់ហាមឃាត់ចំពោះរូបវន្តបុគ្គលនិង/ឬនីតិបុគ្គលបរទេស ។

មាត្រា ២៧៩.-

ទ្រព្យសកម្មរបស់សាខា គឺជាទ្រព្យសកម្មរបស់ក្រុមហ៊ុនដើម ។ ក្រុមហ៊ុនដើមត្រូវទទួលខុសត្រូវលើកាតព្វកិច្ចរបស់សាខា ។

មាត្រា ២៨០.-

សាខាក្រុមហ៊ុន ត្រូវគ្រប់គ្រងដោយនាយកគ្រប់គ្រងម្នាក់ ឬច្រើននាក់ ដែលត្រូវតែងតាំង និងដកហូតដោយក្រុមហ៊ុនដើម ។

មាត្រា ២៨១.-

នាមករណ៍របស់សាខាគឺជានាមករណ៍របស់ក្រុមហ៊ុនដើម ។ នៅពីលើ ឬ នៅពីមុខនាមករណ៍នោះត្រូវសរសេរពាក្យ "សាខាក្រុមហ៊ុន" ។

មាត្រា ២៨២.-

"សាខាក្រុមហ៊ុន" អាចត្រូវរំលាយបានដោយសេចក្តីសម្រេចរបស់ក្រុមហ៊ុនដើម ។

គ- បុត្រសម្ព័ន្ធ

មាត្រា ២៨៣.-

បុត្រសម្ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មបរទេស គឺជាក្រុមហ៊ុនដែលបង្កើតឡើងដោយក្រុមហ៊ុនពាណិជ្ជកម្មបរទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងដែលមានភាគហ៊ុនយ៉ាងតិច ៥១ (ហាសិបមួយ) ភាគរយ ត្រូវបានកាន់កាប់ដោយក្រុមហ៊ុនពាណិជ្ជកម្មបរទេសនោះ ។

មាត្រា ២៨៤.-

បុត្រសម្ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មបរទេស មាននីតិបុគ្គលិកលក្ខណៈដាច់ដោយឡែកពីក្រុមហ៊ុនដើម ចាប់ពីកាលបរិច្ឆេទចុះបញ្ជីពាណិជ្ជកម្ម តាមច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ។

មាត្រា ២៨៥.-

បុត្រសម្ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មបរទេស អាចត្រូវបានបង្កើតឡើងក្នុងទម្រង់ជាក្រុមហ៊ុនសហកម្មសិទ្ធិ ឬ ជាក្រុមហ៊ុនមូលធន ។

មាត្រា ២៨៦.-

បុត្រសម្ព័ន្ធក្រុមហ៊ុនពាណិជ្ជកម្មបរទេស អាចធ្វើគ្រប់សកម្មភាពពាណិជ្ជកម្មជាមុខរបរជាប្រចាំរបស់ខ្លួន ដូចក្រុមហ៊ុនពាណិជ្ជកម្មក្នុងស្រុកដែរ លើកលែងតែសកម្មភាពណា ដែលច្បាប់នៃព្រះរាជាណាចក្រកម្ពុជាហាមឃាត់ចំពោះរូបវន្តបុគ្គល និងនីតិបុគ្គលបរទេស ។

ជំពូកទី ៥

បណ្តឹងជំនួសមុខ

មាត្រា ២៨៧.–

ម្ចាស់ហ៊ុនអាចប្ដឹង ឬ ធ្វើអន្តរាគមន៍ក្នុងនាម និងសិទ្ធិរបស់ក្រុមហ៊ុន ។ ម្ចាស់ហ៊ុនត្រូវបំពេញគ្រប់លក្ខខណ្ឌដូចខាងក្រោម :

ក- ជាម្ចាស់ហ៊ុននៅក្នុងក្រុមហ៊ុន ឬ អ្នកស្នងមរតករបស់ម្ចាស់ហ៊ុន នៅក្នុងអំឡុងពេលដែលការប្ដឹងតវ៉ានោះ កំពុងកើតមានឡើងដោយសារពាណិជ្ជកិច្ចរបស់ក្រុមហ៊ុន ។

ខ- មិនបានបោះឆ្នោតគាំទ្រ ឬមិនបានឱ្យសច្ចានុម័តតាមរបៀបណាផ្សេងទៀតឡើយ ។

គ- បានតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាភិបាល ដើម្បីធ្វើការដោះស្រាយជម្លោះហើយដែលក្រុមប្រឹក្សាភិបាលដោះស្រាយមិនបាន ។

ឃ- ផ្ដល់លិខិតជូនដំណឹងទៅឱ្យក្រុមប្រឹក្សាភិបាល មុនពេលដាក់បណ្ដឹងទៅតុលាការ ។

បណ្ដឹងជំនួសមុខ បន្ទាប់ពីបាននៅតុលាការ មិនត្រូវបានដោះស្រាយដោយគ្មានការព្រមព្រៀងពីតុលាការឡើយ ។

មាត្រា ២៨៨.–

រាល់ប្រាក់សំណងដែលបានមកពីបណ្ដឹងនេះ ត្រូវជាទ្រព្យសម្បត្តិរបស់ក្រុមហ៊ុន ។ ប្រសិនបើបណ្ដឹងបានផ្ដល់ផលដល់ក្រុមហ៊ុន ម្ចាស់ហ៊ុនដែលបានធ្វើបណ្ដឹងជំនួសមុខអាចស្នើសុំទៅតុលាការ ដើម្បីឱ្យខ្លួនបានទទួលសំណងសមស្រប ។

មាត្រា ២៨៩.–

រាល់អភិបាលនិងអ្នកគ្រប់គ្រងក្រុមហ៊ុនដែលកំពុងអនុវត្តតួនាទីរបស់ខ្លួនត្រូវ :

ក- ធ្វើសកម្មភាពស្មោះត្រង់ក្នុងបំណងល្អ ដើម្បីឱ្យមានផលប្រយោជន៍

ខ្ពស់ដល់ក្រុមហ៊ុន ។

ខ- អនុវត្តដោយយកចិត្តទុកដាក់ ព្យាយាម និងជំនាញ ដូចបុគ្គលដែលមានមធ្យ័ត អនុវត្តក្នុងកាលៈទេសៈមួយដូចគ្នាដែរ ។

លក្ខន្តិកៈ ឬ បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន អាចចែងថាគ្រប់ជម្លោះដែលកើតមានឡើងរវាងអភិបាល និងរវាងម្ចាស់ហ៊ុនត្រូវបញ្ជូនទៅមជ្ឈមណ្ឌលមជ្ឈត្តកម្ម ។

ជំពូកទី ៦

ទោសប្បញ្ញត្តិ

មាត្រា ២៩០.-

អ្នកប្រព្រឹត្តបទល្មើស ឬ អ្នកចូលរួមក្នុងការប្រព្រឹត្តបទល្មើស ឬ អ្នកនាំឱ្យមានការប្រព្រឹត្តបទល្មើស ក្នុងការធ្វើរបាយការណ៍ បញ្ជីប្រាក់ចំណូល កំណត់ហេតុ ឬឯកសារផ្សេងៗទៀត ដែលត្រូវផ្ញើទៅក្រសួងពាណិជ្ជកម្ម ឬ ទៅបុគ្គលផ្សេងទៀត ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពី ១.០០០.០០០(មួយលាន)រៀល ដល់ ១០.០០០.០០០ (ដប់លាន)រៀល និង/ឬ ជាប់ពន្ធនាគារពី ១(មួយ) ខែ ដល់ ៦(ប្រាំមួយ) ខែ ដោយមិនទាន់គិតពីសំណងរដ្ឋប្បវេណី ឬ ទោសទណ្ឌដែលមានចែងក្នុងច្បាប់ពាក់ព័ន្ធផ្សេងៗទៀត ។

មាត្រា ២៩១.-

នៅពេលក្រុមហ៊ុនប្រព្រឹត្តបទល្មើស អភិបាល ឬ បុគ្គលិករបស់ក្រុមហ៊ុនណាដែលបានប្រគល់សិទ្ធិឱ្យប្រព្រឹត្តបទល្មើស ឬអនុញ្ញាត ឬបានយល់ព្រមឱ្យប្រព្រឹត្តបទល្មើស ជាអ្នកទទួលខុសត្រូវមួយនៃបទល្មើសនោះ នឹងត្រូវទទួលទោសទណ្ឌដូចមានចែងក្នុងមាត្រា ២៩០ នៃច្បាប់នេះ ។

មាត្រា ២៩២.-

បណ្តឹងចំពោះបទល្មើសដែលបានប្រព្រឹត្តក្រោមច្បាប់នេះ ត្រូវធ្វើឡើងរយៈពេល ៣(បី)ឆ្នាំយ៉ាងយូរ ចាប់តាំងពីថ្ងៃដែលកម្មវត្ថុនៃបណ្តឹងនោះបានកើតឡើង ។

មាត្រា ២៩៣.-

ការខកខានមិនបានអនុវត្តតាមច្បាប់នេះ ដំណោះស្រាយដោយសំណងរដ្ឋប្បវេណីមិនមានឥទ្ធិពលលើបទល្មើសនោះឡើយ ។

មាត្រា ២៩៤.-

ក្រុមហ៊ុន ឬរូបវន្តបុគ្គលដែលមិនបានអនុវត្តដោយគ្មានមូលហេតុត្រឹមត្រូវតាមបញ្ញត្តិស្តីពីការចុះបញ្ជីពាណិជ្ជកម្ម ការតម្កល់ឯកសារទុក ការផ្សព្វផ្សាយ តាមតម្រូវការនៃច្បាប់នេះ ត្រូវផ្តន្ទាទោសតាមមាត្រា ៤៣ និង ៤៤ថ្មី នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម ។

មាត្រា ២៩៥.-

ក្រុមហ៊ុន ឬរូបវន្តបុគ្គលដែលបានប្រព្រឹត្តបទល្មើសនឹងបទប្បញ្ញត្តិនៅក្នុងចំណុច គ ផ្នែកទី ២ នៃជំពូកទី ៣ ដែលពាក់ព័ន្ធនឹងសៀវភៅបញ្ជី និងកំណត់ហេតុ ត្រូវផ្តន្ទាទោសតាមមាត្រា៤៣ និង ៤៤ ថ្មី នៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីណិជ្ជកម្ម ។

មាត្រា ២៩៦.-

ក្រុមហ៊ុនដែលខកខានដោយគ្មានមូលហេតុត្រឹមត្រូវក្នុងការផ្ញើឯកសាររបាយការណ៍ហិរញ្ញវត្ថុទៅម្ចាស់ហ៊ុន និងការបញ្ជូនច្បាប់ចម្លងរបាយការណ៍ហិរញ្ញវត្ថុទៅឱ្យម្ចាស់ហ៊ុនដូចបានចែងក្នុងមាត្រា ២២៧ ត្រូវផ្តន្ទាទោសពិន័យជាទឹកប្រាក់ចំនួនពី ១.០០០.០០០(មួយលាន)រៀល ដល់ ១០.០០០.០០០(ដប់លាន)រៀល ។

មាត្រា ២៩៧.-

ក្រុមហ៊ុនដែលខកខានដោយគ្មានមូលហេតុត្រឹមត្រូវ ក្នុងការបញ្ជូនច្បាប់ចម្លងរបាយការណ៍ហិរញ្ញវត្ថុ ឱ្យទៅមន្ត្រីគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ដូចបានចែងក្នុងមាត្រា ២២៨ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពី ១.០០០.០០០(មួយលាន) រៀល ដល់ ១០.០០០.០០០(ដប់លាន)រៀល ។

មាត្រា ២៩៨.-

សវនករបច្ចុប្បន្ន ឬ សវនករពីមុនរបស់ក្រុមហ៊ុនដែលខកខានដោយគ្មានមូល-ហេតុត្រឹមត្រូវ ក្នុងការបំពេញកាតព្វកិច្ច ការចូលរួមក្នុងមហាសន្និបាតម្ចាស់ហ៊ុនដូចបានចែងក្នុងមាត្រា ២៣៤ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ចំនួនពី ១.០០០.០០០ (មួយលាន)រៀល ដល់១០.០០០.០០០(ដប់លាន)រៀល និង/ ឬ ជាប់ពន្ធនាគារពី ១(មួយ) ខែ ដល់ ៦(ប្រាំមួយ)ខែ ។

មាត្រា ២៩៩.-

មន្ត្រីគ្រប់គ្រងក្រុមហ៊ុននៃក្រសួងពាណិជ្ជកម្ម ដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬ មិនគោរពបទបញ្ជារបស់ក្រសួង ឬរួមគំនិតនឹងអ្នកប្រព្រឹត្តបទល្មើស ឬ ជួយសម្រួលក្នុងការប្រព្រឹត្តបទល្មើសនេះ ត្រូវទទួលការផ្តន្ទាទោសផ្នែករដ្ឋបាល និង/ ឬ ត្រូវចោទប្រកាន់ចំពោះមុខតុលាការ ។

ជំពូកទី ៧

អន្តរប្បញ្ញត្តិ

មាត្រា ៣០០.-

ច្បាប់នេះមិនធ្វើឱ្យប៉ះពាល់ដល់សុពលភាព និង ដល់កិច្ចដំណើរការនៃក្រុមហ៊ុនទាំងអស់ ដែលបានធ្វើការចុះបញ្ជីត្រឹមត្រូវរួចស្រេចហើយនៅក្នុងបញ្ជីពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៣០១.-

ច្បាប់នេះត្រូវអនុវត្តចំពោះរាល់ដំណើរការរបស់ក្រុមហ៊ុនទាំងអស់ ក្នុងទំនាក់ទំនងផ្តល់ឯកសារ និងព័ត៌មានផ្សេងៗជូនក្រសួងពាណិជ្ជកម្ម ។

មាត្រា ៣០២.–

ក្រសួងពាណិជ្ជកម្មត្រូវរៀបចំគំរូលក្ខន្តិកៈនិងបែបបទកែលក្ខន្តិកៈស្របតាមច្បាប់នេះ ដើម្បីផ្សព្វផ្សាយជូនដល់ក្រុមហ៊ុនទាំងឡាយដែលបានចុះបញ្ជីពាណិជ្ជកម្មរួចហើយ ហើយដែលមានបំណងធ្វើការកែប្រែលក្ខន្តិកៈរបស់ខ្លួន ។

ជំពូកទី ៨

អវសានប្បញ្ញត្តិ

មាត្រា ៣០៣.–

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣០៤.–

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០០៥

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស/រកម.០៥០៦.០២៩

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្ដេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ហត្ថលេខា

ចម ប្រសិទ្ធ

លេខ ២៥៥ - ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ២០០៥

អគ្គលេខាធិការរាជរដ្ឋាភិបាល

សាឌី តាន់

នស/រកត/០៦០៥/៤៧៨

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្ត្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា .

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : បំពាក់ **គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា** តាមលំដាប់ថ្នាក់ ជូននាយទាហានជាន់ខ្ពស់ នៃកងយោធពលខេមរភូមិន្ទ ចំនួន ៨៦០ រូប ដែលមានស្នាដៃក្នុងការបំរើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :

ក-គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេរីវឌ្ឍន៍ :

១-នាយឧត្តមសេនីយ៍ **កែ គឹមយ៉ាន** អត្តលេខ ០០០០០៨ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ

២-នាយឧត្តមសេនីយ៍ **ប៉ុល សារឿន** អត្តលេខ ០០០០១៧ អគ្គមេបញ្ជាការរងនិងជានាយសេនាធិការចំរុះ

៣-នាយឧត្តមសេនីយ៍ **មាស សុភា** អត្តលេខ ០០០០១៦ អគ្គមេបញ្ជាការរងនិងជាមេបញ្ជាការកងទ័ពជើងគោក

៤-ឧត្តមសេនីយ៍ឯក **ចាយ សាំងយុន** អត្តលេខ ០០០០១០ រដ្ឋលេខាធិការ ក្រសួងការពារជាតិ

ខ-គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ មហាសេនា :

១-ឧត្តមសេនីយ៍ឯក **មឿង សំផន** អត្តលេខ ០០០០៧១ រដ្ឋលេខាធិការ ក្រសួងការពារជាតិ

២-ឧត្តមសេនីយ៍ឯក **នាង ផាត** អត្តលេខ ០០០០៨០ រដ្ឋលេខាធិការ ក្រសួងការពារជាតិ

៣-ឧត្តមសេនីយ៍ឯក **ស៊ីន្ត គីរី** អត្តលេខ ០០៤២៨៨ រដ្ឋលេខាធិការ ក្រសួងការពារជាតិ

៤-ឧត្តមសេនីយ៍ឯក **ផាន់ ខូន** អត្តលេខ ០០០០៤៩ អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ

៥-ឧត្តមសេនីយ៍ឯក **ឡាយ អ៊ីពិសិដ្ឋ** អត្តលេខ ០០០២៣៥ អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ

៦-ឧត្តមសេនីយ៍ឯក **ចៅ តិរុណ** អត្តលេខ ០០០០៧៥ អគ្គនាយក អគ្គនាយកដ្ឋានសំភារៈបច្ចេកទេស

៧-ឧត្តមសេនីយ៍ឯក **មាស សាម៉ន** អត្តលេខ ០០០០៧៩ អគ្គនាយក អគ្គនាយកដ្ឋានយោធសេវា

៨-ឧត្តមសេនីយ៍ឯក **ស៊ុំ សំណាង** អត្តលេខ ០០០០៧៤ អគ្គនាយក អគ្គនាយកដ្ឋានភស្តុភារហិរញ្ញវត្ថុ

៩-ឧត្តមសេនីយ៍ឯក **ជា តារា** អត្តលេខ ០០០១៨៣ នាយរងសេនាធិការចំរុះ និងជានាយក ទីចាត់ការកលយុទ្ធ អគ្គបញ្ជាការដ្ឋាន

១០-ឧត្តមសេនីយ៍ឯក **ខ្វាន់ សំរាង** អត្តលេខ ០០០១០៨ នាយរងសេនាធិការចំរុះ និងជាមេបញ្ជាការ បញ្ជាការដ្ឋាន វិស្វកម្ម អគ្គបញ្ជាការដ្ឋាន

១១-ឧត្តមសេនីយ៍ឯក **ហ៊ុន ម៉ាណែត** អត្តលេខ ០០០១៨៥ អគ្គមេបញ្ជាការរង នៃកងយោធពលខេមរភូមិន្ទ

១២-ឧត្តមសេនីយ៍ឯក **ជា សារិន** អត្តលេខ០០០០៩០ មេបញ្ជាការរងនិងជានាយសេនាធិការកងទ័ពជើងគោក

១៣-ឧត្តមសេនីយ៍ឯក **សឹង សំណាង** អត្តលេខ ០០០១០១ មេបញ្ជាការ កងទ័ពជើងអាកាស

១៤-ឧត្តមនាវីឯក **អ៊ុង សំខាន់** អត្តលេខ ០០០០៤២ មេបញ្ជាការ កងទ័ពជើងទឹក

១៥-ឧត្តមសេនីយ៍ឯក **សៅ សុខា** អត្តលេខ ០០០១០៥ មេបញ្ជាការ កងរាជអាវុធហត្ថលើផ្ទៃប្រទេស

១៦-ឧត្តមសេនីយ៍ឯក **សំ ឧត្តមផុន** អត្តលេខ ០០០២០៥ អគ្គលេខាធិការ ក្រសួងការពារជាតិ,

១៧-ឧត្តមសេនីយ៍ទោ **ហាក់ សាឡុង** អត្តលេខ ០០០៥១១ រដ្ឋលេខាធិការ ក្រសួងការពារជាតិ

គ-គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

១-ឯកឧត្តម **ស្វាយ ស៊ីថា** អគ្គលេខាធិការក្រុមប្រឹក្សាសាយកងកំលាំងប្រដាប់អាវុធ និងជាអនុរដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី

២-ឧត្តមសេនីយ៍ឯក **ឡុង ឫទ្ធីយ៉ា** អត្តលេខ ០០០១១៨ អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ

៣-ឧត្តមសេនីយ៍ឯក **គៀង សាឡុង** អត្តលេខ ០០០០៣៥ អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ

៤-ឧត្តមសេនីយ៍ឯក **ជុំ សម្បិន** អត្តលេខ ០០០២៤១ អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ

៥-ឧត្តមសេនីយ៍ឯក **ណឹម សុវត្ថិ** អត្តលេខ ០០០០៦៩ ជាទីប្រឹក្សា និងជានាយកខុទ្ទកាល័យ ឯកឧត្តម ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី មានឋានៈស្មើរដ្ឋលេខាធិការ

៦-ឧត្តមសេនីយ៍ឯក **ថោង នៅ** អត្តលេខ ០០០០៤៧ ទីប្រឹក្សា ក្រសួងការពារជាតិ

៧-ឧត្តមសេនីយ៍ឯក **សាញ់ ណេត** អត្តលេខ ០០០០៥៨ ទីប្រឹក្សា ក្រសួងការពារជាតិ

៨-ឧត្តមសេនីយ៍ឯក **ម៉ុន កង** អត្តលេខ ០០០១៦២ ទីប្រឹក្សា ក្រសួងការពារជាតិ

៩-ឧត្តមសេនីយ៍ឯក **ហាម គិន** អត្តលេខ ០០០០៧០ ទីប្រឹក្សា ក្រសួងការពារជាតិ

១០-ឧត្តមសេនីយ៍ឯក **ពុត សំអោក** អត្តលេខ ០០០១៦៣ ទីប្រឹក្សា ក្រសួងការពារជាតិ

១១-ឧត្តមសេនីយ៍ឯក **ខាំ ចាន់** អត្តលេខ ០០០១១៩ ទីប្រឹក្សា ក្រសួងការពារជាតិ

១២-ឧត្តមសេនីយ៍ឯក **ឈិន់ ថៃ** អត្តលេខ ០០០០១៤ ទីប្រឹក្សា ក្រសួងការពារជាតិ

១៣-ឧត្តមសេនីយ៍ឯក **ជឿន ដែល** អត្តលេខ ០០០០១៣ ទីប្រឹក្សា ក្រសួងការពារជាតិ

១៤-ឧត្តមសេនីយ៍ឯក **អៀ ជូគីមម៉េង** អត្តលេខ ០០០០២០ ទីប្រឹក្សា ក្រសួងការពារជាតិ

១៥-ឧត្តមសេនីយ៍ឯក **ស៊ី ស៊ុនតិច** ០០០០៥៦ ទីប្រឹក្សា ក្រសួងការពារជាតិ

១៦-ឧត្តមសេនីយ៍ឯក **លី ឃីម៉ុន** ០០០០៨៣ ទីប្រឹក្សា ក្រសួងការពារជាតិ

១៧-ឧត្តមសេនីយ៍ឯក **អ៊ូ គីមឡេង** ០០០៤៨១ ទីប្រឹក្សា ក្រសួងការពារជាតិ

១៨-ឧត្តមសេនីយ៍ឯក ទេព ប៊ុនឡាយ ០០០០៨២ អគ្គនាយករង អគ្គនាយកដ្ឋានភស្តុភារ-ហិរញ្ញវត្ថុ

១៩-ឧត្តមសេនីយ៍ឯក លី ដេត ០០០០៧៩ អគ្គនាយករង អគ្គនាយកដ្ឋានភស្តុភារ-ហិរញ្ញវត្ថុ

២០-ឧត្តមសេនីយ៍ឯក យឹម សាទី ០០០០៧៧ អគ្គនាយករង អគ្គនាយកដ្ឋានភស្តុភារ-ហិរញ្ញវត្ថុ
និងជានាយក នាយកដ្ឋានប្រេងឥន្ធនៈ

២១-ឧត្តមសេនីយ៍ឯក ឡៀ សុទ្ធ ០០០៧២៩ អគ្គនាយករង អគ្គនាយកដ្ឋានសំភារៈ បច្ចេកទេស

២២-ឧត្តមសេនីយ៍ឯក ផូ ផាន់ ០០០៧២៨ អគ្គនាយករង អគ្គនាយកដ្ឋានសំភារៈ បច្ចេកទេស

២៣-ឧត្តមសេនីយ៍ឯក ផន ណារ៉ា ០០០០៧៨ អគ្គនាយករង អគ្គនាយកដ្ឋានសំភារៈ បច្ចេកទេស
និងជានាយក នាយកដ្ឋានបញ្ជូនសារ

២៤-ឧត្តមសេនីយ៍ឯក ត្រាក់ ម៉ារ៉ាទី ០០០០៨១ អគ្គនាយករង អគ្គនាយកដ្ឋានយោធសេវា

២៥-ឧត្តមសេនីយ៍ឯក កែវ តាំ ០០០២៣២ នាយក នាយកដ្ឋានអធិការកិច្ចទូទៅ

២៦-ឧត្តមសេនីយ៍ឯក មាស សំអុល ០០០២១១ នាយក នាយកដ្ឋានបុគ្គលិក

២៧ ឧត្តមសេនីយ៍ឯក មល់ រឿប ០០០០៤៣ នាយរងសេនាធិការចំរុះ.នាយក នាយកដ្ឋានស្រាវជ្រាវចារកិច្ច អគ្គបញ្ជាការ

២៨ ឧត្តមសេនីយ៍ឯក ញ៉ឹក ហួន ០០០០៥០ នាយរងសេនាធិការចំរុះ អគ្គបញ្ជាការ

២៩ ឧត្តមសេនីយ៍ឯក ឈុំ សុជាតិ ០០០០៣០ នាយរងសេនាធិការចំរុះ,នាយក ទីចាត់ការការងារព្រំដែន អគ្គបញ្ជាការ

៣០ ឧត្តមសេនីយ៍ឯក ហេង បូរិទ្ធ ០០០១៥៧ នាយរងសេនាធិការចំរុះ.នាយសេនាធិការអន្តរាគមន៍ អគ្គបញ្ជាការ

៣១ ឧត្តមសេនីយ៍ឯក ឥត សារ៉ាត់ ០០០៣៣៤ នាយរងសេនាធិការចំរុះ.នាយក ទីចាត់ការហ្វឹកហ្វឺន អគ្គបញ្ជាការ

៣២ ឧត្តមសេនីយ៍ឯក ជាំ ទុន្នី ០០០០៨៨ នាយរងសេនាធិការចំរុះ.នាយក ទីចាត់ការបុគ្គលិក អគ្គបញ្ជាការ

៣៣ ឧត្តមសេនីយ៍ឯក ម៉ក់ សារុន ០០០០៩១ នាយរងសេនាធិការចំរុះ.នាយក ទីចាត់ការចលនូបត្ថម្ភ អគ្គបញ្ជាការ

៣៤ ឧត្តមសេនីយ៍ឯក ហេង ហុង ០០០១២៧ នាយរងសេនាធិការចំរុះ អគ្គបញ្ជាការ

៣៥ ឧត្តមសេនីយ៍ឯក ធូ ស៊ុន ០០០០៨៦ នាយរងសេនាធិការចំរុះ.នាយក ខុទ្ទកាល័យ អគ្គបញ្ជាការ

៣៦ ឧត្តមសេនីយ៍ឯក នុំ សម្បុរ ០០០០៤៤ នាយរងសេនាធិការចំរុះ.នាយក អធិការកិច្ច អគ្គបញ្ជាការ

៣៧ ឧត្តមសេនីយ៍ឯក គឹម ហេង ០០០១១៥ ទីប្រឹក្សា អគ្គបញ្ជាការ

៣៨ ឧត្តមសេនីយ៍ឯក កាន់ វ៉ាត់ ០០០១៥៤ ទីប្រឹក្សា អគ្គបញ្ជាការ

៣៩ ឧត្តមសេនីយ៍ឯក ស៊ូ គីមស៊ុន ០០០១៣០ ទីប្រឹក្សា អគ្គបញ្ជាការ

៤០ ឧត្តមសេនីយ៍ឯក សីវន្ន ធី ០០០០៣៩ មេបញ្ជាការរង កងទ័ពជើងគោក បញ្ជាការដ្ឋានកងទ័ពជើងគោក

៤១ ឧត្តមសេនីយ៍ឯក ខូវ ឈឿន ០០០១៤៣ មេបញ្ជាការរង កងទ័ពជើងគោក បញ្ជាការដ្ឋានកងទ័ពជើងគោក

៤២ ឧត្តមសេនីយ៍ឯក អ៊ុំ ប៊ុត្រា ០០០១៥២ មេបញ្ជាការរង កងទ័ពជើងគោក បញ្ជាការដ្ឋានកងទ័ពជើងគោក

៤៣ ឧត្តមសេនីយ៍ឯក សុខ សាឯម ០០០៣៥១ មេបញ្ជាការរង កងទ័ពជើងគោក បញ្ជាការដ្ឋានកងទ័ពជើងគោក

៤៤ ឧត្តមសេនីយ៍ឯក ជុម ហាក់ ០០០២៧២ មេបញ្ជាការរង កងទ័ពជើងគោក បញ្ជាការដ្ឋានកងទ័ពជើងគោក

៤៥ ឧត្តមសេនីយ៍ឯក មឿន សារិន ០០០០៦៤ មេបញ្ជាការរង កងទ័ពជើងគោក បញ្ជាការដ្ឋានកងទ័ពជើងគោក

៤៦ ឧត្តមសេនីយ៍ឯក ត្រាក់ ចន្ទ្ធី ០០០១៧៧ នាយករង ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

៤៧ ឧត្តមសេនីយ៍ទោ រស់ ពិសាន្ត ០០០០៧២ ទីប្រឹក្សា ក្រសួងការពារជាតិ

៤៨	ឧត្តមសេនីយ៍ទោ	នី	គន	០០៣៨០១	ទីប្រឹក្សា	ក្រសួងការពារជាតិ
៤៩	ឧត្តមសេនីយ៍ទោ	ម៉ៅម	ភ្រាញ	០០០១៧៩	ទីប្រឹក្សា	ក្រសួងការពារជាតិ
៥០	ឧត្តមសេនីយ៍ទោ	តាន់	ឃារីសេធី	០០០១០២	ទីប្រឹក្សា	ក្រសួងការពារជាតិ
៥១	ឧត្តមសេនីយ៍ទោ	ឈរាត្តម	ខារីតទ័ន្ធ	០០០០៣៤	ទីប្រឹក្សា	ក្រសួងការពារជាតិ
៥២	ឧត្តមសេនីយ៍ទោ	ខាត់	ធីន	០០០២១៣	នាយករង	នាយកដ្ឋានបុគ្គលិក
៥៣	ឧត្តមសេនីយ៍ទោ	ឈុន	សារ៉ឿន	០០០៥៣៤	នាយករង	នាយកដ្ឋានបុគ្គលិក
៥៤	ឧត្តមសេនីយ៍ទោ	កៅ	ថ្វី	០០០២៥៧	អគ្គនាយករង	អគ្គនាយកដ្ឋាន ភស្តុភារ-ហិរញ្ញវត្ថុ
៥៥	ឧត្តមសេនីយ៍ទោ	អ៊ុង	ស៊ាន	០០០១១៣	នាយក	វិទ្យាស្ថានយោធាកម្ពុជា
៥៦	ឧត្តមសេនីយ៍ទោ	ម៉ម	សុផាត	០០០១៦១	នាយក	នាយកដ្ឋាននីតិកម្ម
៥៧	ឧត្តមសេនីយ៍ទោ	ឆេព	ចំរើន	០០០២១៥	នាយក	នាយកដ្ឋានភូមិសាស្ត្រ
៥៨	ឧត្តមសេនីយ៍ទោ	គង់	អឿង	០០០២៣៩	នាយករង	នាយកដ្ឋានវិស្វកម្ម
៥៩	ឧត្តមសេនីយ៍ទោ	ស្រី	សនថុន	០០០៧២៣	ប្រធានស្ថាប័ន	អយ្យការយោធា
៦០	ឧត្តមសេនីយ៍ទោ	នំយ	ថុល	០០០០៨៤	ប្រធានស្ថាប័ន	តុលាការយោធា
៦១	ឧត្តមសេនីយ៍ទោ	សាយ	សុខ	០០០០៨៥	ចៅក្រម	តុលាការយោធា
៦២	ឧត្តមសេនីយ៍ទោ	ជាំ	ជារ៉ាវិន្ត	០០០២៩៣	នាយក ទីចាត់ការឃោសនាពតិមាន អគ្គបញ្ជាការ	
៦៣	ឧត្តមសេនីយ៍ទោ	ហ៊ុយ	ទំគច	០០០១៦៨	នាយក មជ្ឈមណ្ឌលស្រាវជ្រាវយុទ្ធសាស្ត្រយោធា អគ្គបញ្ជាការ	
៦៤	ឧត្តមសេនីយ៍ទោ	ឡាញ់	កៅ	០០០១១២	មេបញ្ជាការ បញ្ជាការដ្ឋានវេជ្ជសាស្ត្រ អគ្គបញ្ជាការ	
៦៥	ឧត្តមសេនីយ៍ទោ	យឹម	សាញ់	០០០៣២១	មេបញ្ជាការ បញ្ជាការដ្ឋានកាំភ្លើងធំ អគ្គបញ្ជាការ	
៦៦	ឧត្តមសេនីយ៍ទោ	អ៊ុល	ណារី	០០០១០០	មេបញ្ជាការ បញ្ជាការដ្ឋានការពារអាកាស អគ្គបញ្ជាការ	
៦៧	ឧត្តមសេនីយ៍ទោ	ទំមក	ម៉ុន្នី	០០០៧៤៣	មេបញ្ជាការ បញ្ជាការដ្ឋានបញ្ជូនសារ អគ្គបញ្ជាការ	
៦៨	ឧត្តមសេនីយ៍ទោ	ម៉ម	យឿន	០០០៧២៤	នាយក សាលានាយទាហានចំរុះ អគ្គបញ្ជាការ	
៦៩	ឧត្តមសេនីយ៍ទោ	គីម	ម៉ុនថាង	០០៤៣៥៧	នាយករង ខុទ្ទកាល័យ អគ្គបញ្ជាការ	
៧០	ឧត្តមសេនីយ៍ទោ	ឃួក	ឈាង	០០០១៣៦	មេបញ្ជាការ យោធភូមិភាគទី ១ បញ្ជាការដ្ឋានកងទ័ពជើងគោក	
៧១	ឧត្តមសេនីយ៍ទោ	ជឿន	សុខណ្ណថា	០០០០៣៨	មេបញ្ជាការ យោធភូមិភាគទី ២ បញ្ជាការដ្ឋានកងទ័ពជើងគោក	
៧២	ឧត្តមសេនីយ៍ទោ	ទំគច	សាម្ចុន	០០០១២៩	មេបញ្ជាការ យោធភូមិភាគទី ៣ បញ្ជាការដ្ឋានកងទ័ពជើងគោក	
៧៣	ឧត្តមសេនីយ៍ទោ	ជា	ម៉ន	០០០១៣៥	មេបញ្ជាការ យោធភូមិភាគទី ៤ បញ្ជាការដ្ឋានកងទ័ពជើងគោក	
៧៤	ឧត្តមសេនីយ៍ទោ	ប៊ុន	សេង	០០០១៤៥	មេបញ្ជាការ យោធភូមិភាគទី ៥ បញ្ជាការដ្ឋានកងទ័ពជើងគោក	
៧៥	ឧត្តមសេនីយ៍ទោ	ស្រាម្ភ	ឌិន	០០០០៣៦	មេបញ្ជាការ យោធភូមិភាគពិសេស បញ្ជាការដ្ឋានកងទ័ពជើងគោក	
៧៦	ឧត្តមនាវីទោ	មាស	ឲខ	០០០០៥៤	មេបញ្ជាការរង កងទ័ពជើងទឹក បញ្ជាការដ្ឋានកងទ័ពជើងទឹក	
៧៧	ឧត្តមនាវីទោ	ឆៀ	ចិញ	០០០១៧១	មេបញ្ជាការរង កងទ័ពជើងទឹក បញ្ជាការដ្ឋានកងទ័ពជើងទឹក	

៧៨	ឧត្តមនាវីទោ	សៅ	សារិទ្ធ	០០០២៩៧	មេបញ្ជាការរង នាយសេនាធិការកងទ័ពជើងទឹក
៧៩	ឧត្តមនាវីទោ	អ៊ុក	សីហា	០០០៤៤០	មេបញ្ជាការ មូលដ្ឋានសមុទ្រ បញ្ជាការដ្ឋានកងទ័ពជើងទឹក
៨០	ឧត្តមសេនីយ៍ទោ	គង់	មុនី	០០០១០៣	មេបញ្ជាការរង កងទ័ពជើងអាកាស
៨១	ឧត្តមសេនីយ៍ទោ	ពិន	ណារិទ្ធ	០០០៤៦៥	មេបញ្ជាការរង កងទ័ពជើងអាកាស
៨២	ឧត្តមសេនីយ៍ទោ	សោម	សាឧម	០០០២៩៩	មេបញ្ជាការរង កងទ័ពជើងអាកាស
៨៣	ឧត្តមសេនីយ៍ទោ	យិន	សុខា	០០១៦២០	មេបញ្ជាការរង កងទ័ពជើងអាកាស
៨៤	ឧត្តមសេនីយ៍ទោ	សែស	ចន្ទសត្ថា	០០០៤៦១	មេបញ្ជាការរង នាយសេនាធិការកងទ័ពជើងអាកាស
៨៥	ឧត្តមសេនីយ៍ទោ	ឈិន	ចន្ទពណ៌	០០១១៣៥	មេបញ្ជាការរង កងរាជអាវុធហត្ថលើផ្ទៃប្រទេស
៨៦	ឧត្តមសេនីយ៍ទោ	គេង	ឈួន	០០០៣១៧	មេបញ្ជាការរង កងរាជអាវុធហត្ថលើផ្ទៃប្រទេស
៨៧	ឧត្តមសេនីយ៍ទោ	ចន្ទ	ពិសេន	០០០៣៥៧	មេបញ្ជាការរង.នាយសេនាធិការកងរាជអាវុធហត្ថលើផ្ទៃប្រទេស
៨៨	ឧត្តមសេនីយ៍ទោ	សេង	សុង	០០០៤៤៦	មេបញ្ជាការរង កងរាជអាវុធហត្ថលើផ្ទៃប្រទេស
៨៩	ឧត្តមសេនីយ៍ទោ	អ៊ូ	សារ៉ុម	០០០៣៣២	នាយក ទីចាត់ការហិរញ្ញវត្ថុ អគ្គបញ្ជាការ
៩០	ឧត្តមសេនីយ៍ទោ	ជុំ	តុងហេង	០០០២៨០	នាយក ទីចាត់ការអភិវឌ្ឍន៍ អគ្គបញ្ជាការ
៩១	ឧត្តមសេនីយ៍ទោ	ពត	សុង	០០០៧៣៥	នាយក ទីចាត់ការផែនការ អគ្គបញ្ជាការ
៩២	ឧត្តមសេនីយ៍ទោ	យ៉ាំង	ពិសិដ្ឋ	០០០៣២៨	នាយក ទីចាត់ការបច្ចេកទេស អគ្គបញ្ជាការ
៩៣	ឧត្តមសេនីយ៍ទោ	ជ័យ	សុន	០០០៧៦១	នាយក ទីចាត់ការការពារគីមីសាស្ត្រ អគ្គបញ្ជាការ
៩៤	ឧត្តមសេនីយ៍ទោ	សៅ	គប	០០០៦៦៦	នាយក ទីចាត់ការបំភ័ន្តអក្ខរៈ អគ្គបញ្ជាការ
៩៥	ឧត្តមសេនីយ៍ទោ	ជួ	ហៀង	០០០១៧២	នាយករង ទីចាត់ការកលយុទ្ធ អគ្គបញ្ជាការ
៩៦	ឧត្តមសេនីយ៍ទោ	ម៉ូ	ម៉ុន	០០០៣៧៣	នាយករង ទីចាត់ការកលយុទ្ធ អគ្គបញ្ជាការ
៩៧	ឧត្តមសេនីយ៍ទោ	ទ្រាត់	សំអុល	០០០២៧៦	នាយករង ទីចាត់ការកលយុទ្ធ អគ្គបញ្ជាការ
៩៨	ឧត្តមសេនីយ៍ទោ	ម៉ៅ	សុមណ្ឌា	០០០២៧៥	នាយករង ទីចាត់ការកលយុទ្ធ អគ្គបញ្ជាការ
៩៩	ឧត្តមសេនីយ៍ទោ	ជួង	សុខុន	០០០១៤៦	នាយករង ទីចាត់ការការងារព្រំដែន អគ្គបញ្ជាការ
១០០	ឧត្តមសេនីយ៍ទោ	អ៊ុយ	សារិន	០០០១២៤	នាយករង ទីចាត់ការការងារព្រំដែន អគ្គបញ្ជាការ
១០១	ឧត្តមសេនីយ៍ទោ	គីម	ម៉ិនធឿន	០០០២៧៣	នាយសេនាធិការរង កងអន្តរាគមន៍ អគ្គបញ្ជាការ
១០២	ឧត្តមសេនីយ៍ទោ	គី	គាត	០០០១១១	នាយសេនាធិការរង កងអន្តរាគមន៍ អគ្គបញ្ជាការ
១០៣	ឧត្តមសេនីយ៍ទោ	សែម	សុមណ្ឌាលី	០០០៣១០	មេបញ្ជាការរង បញ្ជាការដ្ឋានវិស្វកម្ម អគ្គបញ្ជាការ
១០៤	ឧត្តមសេនីយ៍ទោ	សុខ	ផល	០០០១៤២	មេបញ្ជាការរង បញ្ជាការដ្ឋានវិស្វកម្ម អគ្គបញ្ជាការ
១០៥	ឧត្តមសេនីយ៍ទោ	សួង	យុទ្ធី	០០០៣០៨	មេបញ្ជាការរង បញ្ជាការដ្ឋានវិស្វកម្ម អគ្គបញ្ជាការ
១០៦	ឧត្តមសេនីយ៍ទោ	ឃ្លី	ជុំទីណា	០០៤៤២៧	មេបញ្ជាការរង បញ្ជាការដ្ឋានវិស្វកម្ម អគ្គបញ្ជាការ
១០៧	ឧត្តមសេនីយ៍ទោ	ពៅ	ផារី	០០០៣១១	មេបញ្ជាការរង និងជានាយសេនាធិការ បញ្ជាការដ្ឋានវិស្វកម្ម អគ្គបញ្ជាការ
១០៨	ឧត្តមសេនីយ៍ទោ	ទ្រាត់	សុមណ្ឌា	០០០០៨៦	នាយសេនាធិការរង កងទ័ពជើងគោក បញ្ជាការដ្ឋានកងទ័ពជើងគោក
១០៩	ឧត្តមសេនីយ៍ទោ	ទឹម	ចាសរឃឿន	០០០១១៦	នាយសេនាធិការរង និងជា នាយកការិយាល័យទី ៣ បញ្ជាការដ្ឋានកងទ័ពជើងគោក

១១០	ឧត្តមសេនីយ៍ទោ	ម៉ៅ	ចែន	០០០១១៧	នាយសេនាធិការរង និងជា នាយអធិការកិច្ច បញ្ជាការដ្ឋានកងទ័ពជើងគោក
១១១	ឧត្តមសេនីយ៍ទោ	ស៊ីត	ហ៊ុន	០០០១៦៦	នាយសេនាធិការរង និងជា នាយការិយាល័យទី ២ បញ្ជាការដ្ឋានកងទ័ពជើងគោក
១១២	ឧត្តមសេនីយ៍ទោ	ចាប	ចាន់ធី	០០០២៨៧	នាយសេនាធិការរង និងជា នាយការិយាល័យទី ៥ បញ្ជាការដ្ឋានកងទ័ពជើងគោក
១១៣	ឧត្តមសេនីយ៍ទោ	ចាន់	សុគន្ធា	០០០៣៣៥	នាយសេនាធិការរង និងជា នាយការិយាល័យហ្វឹកហ្វឺន បញ្ជាការដ្ឋានកងទ័ពជើងគោក
១១៤	ឧត្តមសេនីយ៍ទោ	ម៉ាត់	ចំរុញ	០០០៤៣៩	នាយសេនាធិការរង និងជា នាយការិយាល័យយោធាតំបន់ បញ្ជាការដ្ឋានកងទ័ពជើងគោក
១១៥	ឧត្តមសេនីយ៍ទោ	អ៊ុច	ចាន់ថា	០០០៤៥១	នាយសេនាធិការរង និងជា មេបញ្ជាការ បញ្ជាការដ្ឋានវិស្វកម្ម បញ្ជាការដ្ឋានកងទ័ពជើងគោក
១១៦	ឧត្តមសេនីយ៍ទោ	អួន	លន	០០០២៧៧	នាយសេនាធិការរង និងជា នាយការិយាល័យទី ១ បញ្ជាការដ្ឋានកងទ័ពជើងគោក
១១៧	ឧត្តមសេនីយ៍ទោ	សេង	សរី	០០០០៥៨	នាយសេនាធិការរង និងជា នាយការិយាល័យការពារព្រំដែន បញ្ជាការដ្ឋានកងទ័ពជើងគោក
១១៨	ឧត្តមសេនីយ៍ទោ	ចាន់	រ៉ា	០០០៣៤១	នាយសេនាធិការរង កងទ័ពជើងគោក
១១៩	ឧត្តមសេនីយ៍ទោ	ព្រហ្ម	មរណៈ	០០០១៤៤	នាយសេនាធិការរង កងទ័ពជើងគោក
១២០	ឧត្តមសេនីយ៍ទោ	សុខ	ឈាន	០០៣៨១៥	នាយសេនាធិការរង កងទ័ពជើងគោក
១២១	ឧត្តមសេនីយ៍ទោ	អ៊ិន	ហឿន	០០៤៣៥២	នាយសេនាធិការរង កងទ័ពជើងគោក
១២២	ឧត្តមសេនីយ៍ទោ	ទឹម	ប៊ុន	០០៤៣៥៩	នាយសេនាធិការរង កងទ័ពជើងគោក
១២៣	ឧត្តមសេនីយ៍ត្រី	មាស	វណ្ណា	០០៤៣១៩	អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ
១២៤	ឧត្តមសេនីយ៍ត្រី	ពេជ្រ	សុជេដ្ឋា	០០៤៣២០	អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ
១២៥	ឧត្តមសេនីយ៍ត្រី	សុខ	ភាព	០០៣៨១១	នាយករង ទីចាត់ការការងារព្រំដែន អគ្គបញ្ជាការ
១២៦	ឧត្តមសេនីយ៍ត្រី	គង់	វណ្ណឌី	០០២៥១៤	លេខាផ្ទាល់ឧ.ឧ អគ្គមេបញ្ជាការរង .នាយសេនាធិការចំរុះ អគ្គបញ្ជាការ
១២៧	ឧត្តមសេនីយ៍ត្រី	កែវ	ពន្យ	០០១១៧២	មេបញ្ជាការរង យោធភូមិភាគទី ៣ បញ្ជាការដ្ឋានកងទ័ពជើងគោក
១២៨	ឧត្តមសេនីយ៍ត្រី	ស៊ីត	ស៊ីនិត	០០០៤៤៨	មេបញ្ជាការអង្គរក្ស កងពលតូចលេខ ៧០ អគ្គបញ្ជាការ
១២៩	ឧត្តមសេនីយ៍ត្រី	អ៊ុត	សាខន	០០០៣៧៤	ឧបការីសម្តេចព្រះប្រធានរដ្ឋសភា ទទួលបន្ទុកមេបញ្ជាការអង្គរក្ស អគ្គបញ្ជាការ
១៣០	ឧត្តមសេនីយ៍ត្រី	ឈឿន	ចាន់ថន	០០៣៣៦១	មេបញ្ជាការរង កងពលតូចលេខ៧០.មេ-អង្គរក្សសម្តេចព្រឹទ្ធសភា អគ្គបញ្ជាការ
១៣១	ឧត្តមសេនីយ៍ត្រី	ឡឿង	សារុន	០០២៣៣២	មេបញ្ជាការរងអង្គរក្ស សម្តេចនាយករដ្ឋមន្ត្រី អគ្គបញ្ជាការ
១៣២	ឧត្តមសេនីយ៍ត្រី	ខែម	ថា	០០០៤៤២	មេបញ្ជាការរង កងពលតូចលេខ ៧០ អគ្គបញ្ជាការ
១៣៣	ឧត្តមសេនីយ៍ត្រី	ជួង	សរី	០០០៤៤៧	មេបញ្ជាការរង កងពលតូចលេខ ៧០ អគ្គបញ្ជាការ
១៣៤	ឧត្តមសេនីយ៍ត្រី	ទៀង	និត្យ	០០១០៨៣	មេបញ្ជាការរង កងពលតូចលេខ ៧០ អគ្គបញ្ជាការ
១៣៥	ឧត្តមសេនីយ៍ត្រី	ឈុន	ហឿន	០០២៣៦០	មេបញ្ជាការរង កងពលតូចលេខ ៧០ អគ្គបញ្ជាការ
១៣៦	ឧត្តមសេនីយ៍ត្រី	ចាន់	វណ្ណា	០០២៣១៨	មេបញ្ជាការរង និងជា នាយសេនាធិការ កងពលតូចលេខ ៧០ អគ្គបញ្ជាការ

ឃ-គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា

១	ឧត្តមសេនីយ៍ឯក	ជុំ	ឈាង	០០០០៧៤	នាយរងសេនាធិការចំរុះ អគ្គបញ្ជាការ
២	ឧត្តមសេនីយ៍ទោ	លឹម	លាងសែ	០០១១៦៩	នាយករង ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
៣	ឧត្តមសេនីយ៍ទោ	មាស	មុត	០០៣៨០៣	ទីប្រឹក្សា ក្រសួងការពារជាតិ

៤	ឧត្តមសេនីយ៍ទោ ចាប	គុនី	០០០៣៨៩	ទីប្រឹក្សា	ក្រសួងការពារជាតិ
៥	ឧត្តមសេនីយ៍ទោ មិន	សារឿន	០០០២០០	ទីប្រឹក្សា	ក្រសួងការពារជាតិ
៦	ឧត្តមសេនីយ៍ទោ ឃិន	យាន	០០០១៣៩	ទីប្រឹក្សា	ក្រសួងការពារជាតិ
៧	ឧត្តមសេនីយ៍ទោ ឃុត	សំអាន់	០០០១៩៦	ទីប្រឹក្សា	ក្រសួងការពារជាតិ
៨	ឧត្តមសេនីយ៍ទោ ទាំង	ធី	០០០១៩៧	ទីប្រឹក្សា	ក្រសួងការពារជាតិ
៩	ឧត្តមសេនីយ៍ទោ សូ	ជី	០០០២០១	ទីប្រឹក្សា	ក្រសួងការពារជាតិ
១០	ឧត្តមសេនីយ៍ទោ ទៀ	គឹមឃាន	០០០៣៤០	ទីប្រឹក្សា	ក្រសួងការពារជាតិ
១១	ឧត្តមសេនីយ៍ទោ អន	មុន្នី	០០០២៦៩	ទីប្រឹក្សា	ក្រសួងការពារជាតិ
១២	ឧត្តមសេនីយ៍ទោ ចៅ	សែនជំនោរ	០០០១៩៨	ទីប្រឹក្សា	ក្រសួងការពារជាតិ
១៣	ឧត្តមសេនីយ៍ទោ ឡោ	លីថុង	០០០២១៤	អគ្គលេខាធិការរង	ក្រសួងការពារជាតិ
១៤	ឧត្តមសេនីយ៍ទោ រស់	ឆោម	០០១១៦៧	អគ្គលេខាធិការរង	ក្រសួងការពារជាតិ
១៥	ឧត្តមសេនីយ៍ទោ ម៉ុំ	លីមឿន	០០០២០៧	អគ្គលេខាធិការរង	ក្រសួងការពារជាតិ
១៦	ឧត្តមសេនីយ៍ទោ ឈាំង	ធរ៉ូ	០០០៥២៥	អគ្គលេខាធិការរង	ក្រសួងការពារជាតិ និងជា នាយក នាយកដ្ឋានកិច្ចការរដ្ឋបាល
១៧	ឧត្តមសេនីយ៍ទោ ឃុន	ទុយ	០០០២៤៦	អគ្គលេខាធិការរង	ក្រសួងការពារជាតិ
១៨	ឧត្តមសេនីយ៍ទោ ឈឹម	រចនា	០០០២០៨	អគ្គលេខាធិការរង	ក្រសួងការពារជាតិ
១៩	ឧត្តមសេនីយ៍ទោ ម៉ែត	នរិន្ទ្រ	០០០២៣៥	អគ្គនាយករង	អគ្គនាយកដ្ឋានភស្តុភារ-ហិរញ្ញវត្ថុនិងជា នាយក នាយកដ្ឋានវិស្វកម្ម
២០	ឧត្តមសេនីយ៍ទោ នាង	អេង	០០០២៤០	អគ្គនាយករង	អគ្គនាយកដ្ឋានយោធសេវានិងជា នាយក នាយកដ្ឋានអប់រំ
២១	ឧត្តមសេនីយ៍ទោ ស្វួន	សំណាង	០០០២០៦	អគ្គនាយករង	អគ្គនាយកដ្ឋានយោធសេវានិងជា នាយក នាយកដ្ឋានទាក់ទងអន្តរជាតិ
៧	វរនាវីត្រី	ខាត់ សួយ	អត្តលេខ	០១៥១៤៣	នាយផ្នែកបណ្តុះបណ្តាលការិយាល័យទី១ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
៨	វរនាវីត្រី	ធី សុខា	អត្តលេខ	០១០២៧៤	នាយផ្នែកអប់រំចិត្តសាស្ត្រការិយាល័យទី៥ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
៩	អនុនាវីឯក	ញាណ ចន្ថា	អត្តលេខ	០១៥០៣៨	ជំនួយការហិរញ្ញវត្ថុ ការិយាល័យហិរញ្ញវត្ថុ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១០	អនុនាវីឯក	ឌុច ម៉ូរ៉ានី	អត្តលេខ	០១៤៩៩៧	នាយរងការិយាលយបំភ័ន្តអក្សរ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១១	អនុនាវីឯក	សេក គន្ធី	អត្តលេខ	០១៤៩៩១	ជំនួយកាយអត្តសញ្ញាណប័ណ្ណ ការិយាល័យទី១ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១២	អនុនាវីឯក	សេង ទាសនា	អត្តលេខ	០៤១១២៨	ជំនួយការតែងតាំង ការិយាល័យទី១ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៣	អនុនាវីឯក	សន សុវណ្ណារ៉ា	អត្តលេខ	០៣១១២៤	ជំនួយការតែងតាំង ការិយាល័យទី១ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៤	អនុនាវីឯក	តាក ផល្លា	អត្តលេខ	០៣០៩១២	ជំនួយការបុគ្គលិក ការិយាល័យទី១ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៥	អនុនាវីឯក	សរ សុផុន	អត្តលេខ	០៣០៩១៤	ជំនួយការសន្តិសុខ ការិយាល័យទី១ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៦	អនុនាវីឯក	ហ៊ឹង ធារី	អត្តលេខ	០៤២៨៣៧	ជំនួយការស្រាវជ្រាវ ការិយាល័យទី២ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៧	អនុនាវីឯក	ម៉ី សារុន	អត្តលេខ	០២៥៦៩១	ជំនួយការប្រតិបត្តិការសឹក ការិយាល័យទី៣ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៨	អនុនាវីឯក	ថាត់ ធិរៈ	អត្តលេខ	០១៥០២៦	ជំនួយការសំភារៈ ការិយាលយបច្ចេកទេស បញ្ជាការដ្ឋាន កងទ័ពជើងទឹក

១៩	អនុនាវីឯក	គង់ ឈូន	អត្តលេខ	០១៩០៥១	ជំនួយការបច្ចេកទេស ការិយាល័យបច្ចេកទេស បញ្ជាការដ្ឋាន កងទ័ពជើងទឹក
២០	អនុនាវីឯក	ជា ឧល	អត្តលេខ	០១៩០៤១	ជំនួយការវិស្វកម្ម ការិយាល័យវិស្វកម្ម បញ្ជាការដ្ឋាន កងទ័ពជើងទឹក
២១	អនុនាវីឯក	ឈឹម ស៊ុណាត	អត្តលេខ	០១៩១៣៧	ជំនួយការអធិការកិច្ច អធិការកិច្ច បញ្ជាការដ្ឋាន កងទ័ពជើងទឹក
២២	អនុនាវីឯក	ឃិន សុផល	អត្តលេខ	០៣១១៣៦	ជំនួយការការពារអាកាសការិយាល័យការពារអាកាស បញ្ជាការដ្ឋាន កងទ័ពជើងទឹក
២៣	អនុនាវីឯក	រស់ សារឹម	អត្តលេខ	០១៩០៣៩	ជំនួយការហិរញ្ញវត្ថុ ការិយាល័យហិរញ្ញវត្ថុ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
២៤	អនុនាវីឯក	ហែម ឈឿន	អត្តលេខ	០១៩០៣២	ជំនួយការហ្វឹកហ្វឺន ការិយាល័យហ្វឹកហ្វឺន បញ្ជាការដ្ឋាន កងទ័ពជើងទឹក
២៥	អនុនាវីឯក	អ៊ុច សារ៉ាន់	អត្តលេខ	០១៩១៦២	ជំនួយការអភិវឌ្ឍន៍ ការិយាល័យអភិវឌ្ឍន៍ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
២៦	អនុនាវីឯក	សំ តែម	អត្តលេខ	០១៩១៤៣	ជំនួយការឃោសនាពត៌មាន ការិយាល័យទី៥ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
២៧	អនុនាវីឯក	ឡាយ ឡេង	អត្តលេខ	០១៩០៥៨	នាយគ្រូកាំភ្លើងធំ សាលាកងទ័ពជើងទឹក បញ្ជាការដ្ឋាន កងទ័ពជើងទឹក
២៨	អនុនាវីឯក	ម៉ុច ហៀម	អត្តលេខ	០១៩០៥០	នាយរងលេខាធិការដ្ឋាន សាលាកងទ័ពជើងទឹក បញ្ជាការដ្ឋាន កងទ័ពជើងទឹក
២៩	អនុនាវីឯក	ម៉ម សារិនទ្រី	អត្តលេខ	០១៨៩៨១	វេជ្ជបណ្ឌិត សាលាកងទ័ពជើងទឹក បញ្ជាការដ្ឋាន កងទ័ពជើងទឹក
៣០	អនុនាវីឯក	សោម សាម៉ន	អត្តលេខ	០១៩០៤៧	នាយផ្នែកជុសជុលរថយន្ត រោងជាង បញ្ជាការដ្ឋាន កងទ័ពជើងទឹក
៣១	អនុនាវីឯក	ម៉ុត ចន្ថា	អត្តលេខ	០១៩១២២	នាយរងការិយាលយទី១ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៣២	អនុនាវីឯក	នី ផុន	អត្តលេខ	០៣១០៥៤	នាយរងលេខាធិការដ្ឋាន មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៣៣	អនុនាវីឯក	មង្ស សារិន	អត្តលេខ	០១៩១៤០	នាយរងការិយាល័យទី២ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៣៤	អនុនាវីឯក	ម៉ែន សុខុន	អត្តលេខ	០១៩១១៩	មេបញ្ជាការរងកងរ៉ាដាលេខ១០ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៣៥	អនុនាវីឯក	ម៉ក់ ចន្ធា	អត្តលេខ	០០៣០៦០	នាយរងការិយាល័យហ្វឹកហ្វឺន មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៣៦	អនុនាវីឯក	គង់ ស៊ីន	អត្តលេខ	០៣១០២២	នាយរងការិយាល័យហ្វឹកហ្វឺន មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៣៧	អនុនាវីឯក	ស៊ូ សុខេន	អត្តលេខ	០៣១០៥៧	នាយរងការិយាល័យហិរញ្ញវត្ថុ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៣៨	អនុនាវីឯក	ទឹម សំណាង	អត្តលេខ	០១៩០៨៩	មេបញ្ជាការរងកងការពារកោះកុងក្រៅលេខ២ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៣៩	អនុនាវីឯក	ហេង សុផល	អត្តលេខ	០១៩០៩៣	នាយសេនាធិការកងការពារកោះតាងលេខ៣ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៤០	អនុនាវីឯក	ម៉ែន ភារុណ	អត្តលេខ	០១៩០៩៤	មេបញ្ជាការរងកងការពារកោះរ៉ុងសន្លឹមលេខ៤ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៤១	អនុនាវីឯក	អ៊ុន អាន	អត្តលេខ	០៣១០០២	នាយសេនាធិការកងការពារកោះរ៉ុងសន្លឹមលេខ៤ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៤២	អនុនាវីឯក	ចាន់ សារិដ្ឋ	អត្តលេខ	០៣១០១៧	នាយរងការិយាល័យទី៤ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៤៣	អនុនាវីឯក	អោក សុផាត	អត្តលេខ	០៣១០៨១	នាយសេនាធិការកងនាវាល្បាតឆ្នេរលេខ៦ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៤៤	អនុនាវីឯក	ស្រី ចាន់ធុល	អត្តលេខ	០១៩១០៥	មេបញ្ជាការរងកងនាវាប្រដេញលេខ៧ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៤៥	អនុនាវីឯក	ភច សុខុន	អត្តលេខ	០៣១០៩៥	មេបញ្ជាការនាវា១១៣៣កងនាវាប្រដេញ ៧ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៤៦	អនុនាវីឯក	ជា គោម	អត្តលេខ	០៣១០៨០	មេបញ្ជាការនាវា១១៣២កងនាវាប្រដេញ ៧ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៤៧	អនុនាវីឯក	ហេង ជេង	អត្តលេខ	០៥១១១៣	មេបញ្ជាការរងកងកាំភ្លើងធំលេខ៨ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក

៤៨	អនុនាវីឯក	ប្រាក់ ថន	អត្តលេខ	០៤២៧៨៣	នាយសេនាធិការកងកាំភ្លើងធំលេខ៨ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៤៩	អនុនាវីឯក	ប្រាក់ សម្បត្តិ	អត្តលេខ	០១៥១៧៧	មេបញ្ជាការរងកងកាំភ្លើងធំការពារអាកាស ៩ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៥០	អនុនាវីឯក	អឿ សារឿន	អត្តលេខ	០៣០៩៩៦	មេបញ្ជាការរងកងកាំភ្លើងធំការពារអាកាស ៩ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៥១	អនុនាវីឯក	ភាន់ ចាន់ខាសនា	អត្តលេខ	០៣១០៧៨	នាយសេនាធិការកងកាំភ្លើងធំការពារអាកាស មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៥២	អនុនាវីឯក	ម៉ែន សុវណ្ណារិទ្ធ	អត្តលេខ	០១៥១២១	នាយសេនាធិការកងវ៉ាដាលេខ១០ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៥៣	អនុនាវីឯក	ខ្ញឹម យ៉ានី	អត្តលេខ	០៤២៨៨៨	មេបញ្ជាការរងកងនាវាដឹកជញ្ជូន មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៥៤	អនុនាវីឯក	កែវ ទិចិត្រា	អត្តលេខ	០៣១១៤០	មេបញ្ជាការរងកងការពារកោះរ៉ុងលេខ១ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៥៥	អនុនាវីឯក	កែវ ឡា	អត្តលេខ	០៤២៨១៨	មេបញ្ជាការរងកងនាវាដឹកជញ្ជូន មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៥៦	អនុនាវីឯក	សៅ សុផល	អត្តលេខ	០១៥០៧៦	នាយរងការិយាល័យទី២ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៥៧	អនុនាវីឯក	ព្រុំ ចាន់ចំរើន	អត្តលេខ	០៣១០១២	នាយរងការិយាល័យទី៣ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៥៨	អនុនាវីទោ	ទ៉ាត សារិទ្ធ	អត្តលេខ	០៤២៨៣៥	ជំនួយការបណ្តុះបណ្តាល ការិយាល័យទី១ បញ្ជាការដ្ឋានកងទ័ពជើងទឹក
៥៩	អនុនាវីទោ	ហ៊ុន សម្បត្តិ	អត្តលេខ	០៣១១៤៧	ជំនួយការប្រេងឥន្ធនៈ ការិយាល័យទី៤ បញ្ជាការដ្ឋានកងទ័ពជើងទឹក
៦០	អនុនាវីទោ	ប៊ុន នី	អត្តលេខ	០៣១១៣៥	ជំនួយការអភិវឌ្ឍន៍ ការិយាល័យអភិវឌ្ឍន៍ បញ្ជាការដ្ឋានកងទ័ពជើងទឹក
៦១	អនុនាវីទោ	ថាច់ កុសល់	អត្តលេខ	០៣១១២២	ជំនួយការហិរញ្ញវត្ថុ ការិយាល័យហិរញ្ញវត្ថុ បញ្ជាការដ្ឋានកងទ័ពជើងទឹក
៦២	អនុនាវីទោ	ប្រាក់ សុខឿន	អត្តលេខ	០៣១៤៩០	ជំនួយការសុខាភិបាល ការិយាល័យសុខាភិបាល បញ្ជាការដ្ឋានកងទ័ពជើងទឹក
៦៣	អនុនាវីទោ	យោគ យឿន	អត្តលេខ	០៣១១៨០	មេបញ្ជាការរង អ.ធំកងការពារ បញ្ជាការដ្ឋានកងទ័ពជើងទឹក
៦៤	អនុនាវីទោ	ហ៊ុន គីមថូ	អត្តលេខ	០៣០៩៥៣	ជំនួយការហិរញ្ញវត្ថុ សាលាកងទ័ពជើងទឹក បញ្ជាការដ្ឋានកងទ័ពជើងទឹក
៦៥	អនុនាវីទោ	ថៃ ចន្ថា	អត្តលេខ	០៣០៩៧៩	គ្រូឋានលេខា សាលាកងទ័ពជើងទឹក បញ្ជាការដ្ឋានកងទ័ពជើងទឹក
៦៦	អនុនាវីទោ	សុខ ប៊ុនធឿន	អត្តលេខ	០៣០៤៧៤	គ្រូចំណេះទូទៅ សាលាកងទ័ពជើងទឹក បញ្ជាការដ្ឋានកងទ័ពជើងទឹក
៦៧	អនុនាវីទោ	និត្យ សុផល	អត្តលេខ	០៣០៩៧៣	គ្រូនាំផ្លូវនាវា សាលាកងទ័ពជើងទឹក បញ្ជាការដ្ឋានកងទ័ពជើងទឹក
៦៨	អនុនាវីទោ	ព្រាប សាម៉ន	អត្តលេខ	០៣០៩៨៥	គ្រូរ៉ាដា សាលាកងទ័ពជើងទឹក បញ្ជាការដ្ឋានកងទ័ពជើងទឹក
៦៩	អនុនាវីទោ	ស្រី រិន	អត្តលេខ	០៣០៩៥៨	ជំនួយការបុគ្គលិក សាលាកងទ័ពជើងទឹក បញ្ជាការដ្ឋានកងទ័ពជើងទឹក
៧០	អនុនាវីទោ	ហែម ពិសិដ្ឋ	អត្តលេខ	០១៥១៣០	មេបញ្ជាការអ.ធំដឹកជញ្ជូន២កងនាវាល្បាតទន្លេ បញ្ជាការដ្ឋានកងទ័ពជើងទឹក
៧១	អនុនាវីទោ	ឌី ឆន	អត្តលេខ	០១៥១៤៩	មេបញ្ជាការអ.ធំដឹកជញ្ជូន៤កងនាវាល្បាតទន្លេ បញ្ជាការដ្ឋានកងទ័ពជើងទឹក
៧២	អនុនាវីទោ	ជា ចំរើន	អត្តលេខ	០១៥១៥២	មេបញ្ជាការរងអ.ធំ១ កងនាវាល្បាតទន្លេ បញ្ជាការដ្ឋានកងទ័ពជើងទឹក
៧៣	អនុនាវីទោ	សៅ សុខន	អត្តលេខ	០៣១១៧៣	មេបញ្ជាការរងអ.ធំ១ កងនាវាល្បាតទន្លេ បញ្ជាការដ្ឋានកងទ័ពជើងទឹក
៧៤	អនុនាវីទោ	ស៊ុំ សំណាង	អត្តលេខ	០១៥១៦៤	បញ្ជាការរងអ.ធំដឹកជញ្ជូន២កងនាវាល្បាតទន្លេ បញ្ជាការដ្ឋានកងទ័ពជើងទឹក
៧៥	អនុនាវីទោ	ជាម សុគឿន	អត្តលេខ	០៣០៩៨៨	ជំនួយការបុគ្គលិក ការិយាល័យទី១ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៧៦	អនុនាវីទោ	ហែម ចាន់	អត្តលេខ	០៣០៩៩៨	ជំនួយការបណ្តុះបណ្តាល ការិយាល័យទី១ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក

៧៧	អនុនាវីទោ	កៅ ឫទ្ធី	អត្តលេខ	០៤២៧០៥	ជំនួយការតែងតាំង ការិយាល័យទី១ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៧៨	អនុនាវីទោ	អ៊ុក វឌ្ឍា	អត្តលេខ	០៣១០៣០	មេបញ្ជាការនាវា១១០៣ កងនាវាល្បាតឆ្នេរ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៧៩	អនុនាវីទោ	សេង ឫទ្ធី	អត្តលេខ	០១៥១០២	ជំនួយការឯកសារ ការិយាល័យទី១ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៨០	អនុនាវីទោ	ថុន ម៉ុនឈឿន	អត្តលេខ	០៣១០២៤	ជំនួយការគោលនយោបាយ ការិយាល័យទី៥ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៨១	អនុនាវីទោ	ឌុំ ទ៉ាត	អត្តលេខ	០៣១១៨៥	មេបញ្ជាការអ.ធ១ កងកាំភ្លើងធំ ១៥៥មម មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៨២	អនុនាវីទោ	ជាំ ឈឿង	អត្តលេខ	០៣១០៤៤	ពេទ្យមធ្យម គិលានដ្ឋាន មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៨៣	អនុនាវីទោ	សំ សុខា	អត្តលេខ	០៣១០៤២	ពេទ្យមធ្យម គិលានដ្ឋាន មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៨៤	អនុនាវីទោ	ញ៉ឹម ស៊ិន	អត្តលេខ	០៣១០៦៧	មេបញ្ជាការអ.ធ២កងការពារកោះកុងក្រៅ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៨៥	អនុនាវីទោ	យិន សារ៉ុន	អត្តលេខ	០៣១០៦៨	មេបញ្ជាការអ.ធ១កងការពារកោះកុងក្រៅ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៨៦	អនុនាវីទោ	ស្រី ចណ្ណា	អត្តលេខ	០៣០៩៩២	ជំនួយការសរសេរ ក្រិត្យវិន័យការិយាល័យទី១ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៨៧	អនុនាវីទោ	ឆាយ សុជា	អត្តលេខ	០៣១០៨៧	មេបញ្ជាការនាវា១១១២កងនាវាល្បាតឆ្នេរ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៨៨	អនុនាវីទោ	សរ សុផាន	អត្តលេខ	០៣១០៧២	មេបញ្ជាការអ.ធ២កងការពារកោះតាង មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៨៩	អនុនាវីទោ	ព្រហ្ម សេង	អត្តលេខ	០៣១០៧១	មេបញ្ជាការអ.ធ៣កងការពារកោះតាង មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៩០	អនុនាវីទោ	សូ ចិន្តា	អត្តលេខ	០៣១០៧៣	មេបញ្ជាការអ.ធ១កងការពារកោះរ៉ុងសន្លឹម មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៩១	អនុនាវីទោ	សួន សុខុម	អត្តលេខ	០៣១០៧៤	មេបញ្ជាការអ.ធ៣កងការពារកោះរ៉ុងសន្លឹម មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៩២	អនុនាវីទោ	ពៅ ម៉ុនឈឿន	អត្តលេខ	០៣១០៧៥	មេបញ្ជាការអ.ធ៣កងការពារកោះពូលូវៃ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៩៣	អនុនាវីទោ	ម៉ែន សារ៉ាត់	អត្តលេខ	០៤២៧២៥	មេបញ្ជាការអ.ធ១កងការពារកោះពូលូវៃ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៩៤	អនុនាវីទោ	ម៉ុំ សាឆាន	អត្តលេខ	០៤២៧៦៧	មេបញ្ជាការនាវា១១២១កងនាវាប្រដេញ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៩៥	អនុនាវីទោ	ហ៊ីង សាមុត	អត្តលេខ	០៣១១០០	មេបញ្ជាការអ.ធ២កងកាំភ្លើងធំការពារអាកាស មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៩៦	អនុនាវីទោ	សោមសាម៉ន	អត្តលេខ	០៤២៧៩០	មេបញ្ជាការអធំ៣កងកាំភ្លើងធំការពារអាកាស មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៩៧	អនុនាវីទោ	សាយ ខេង	អត្តលេខ	០៣១១០៤	មេ.ស្ថានីយ៍រ៉ាដាសង្កេតការផ្ទៃអាកាសកងរ៉ាដា មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៩៨	អនុនាវីទោ	ជុំន សុផាត	អត្តលេខ	០៣១០៩៩	នាយរងផ្នែកការពារអាកាស មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
៩៩	អនុនាវីទោ	នង ជា	អត្តលេខ	០៤២៦៩៨	នាយរងផ្នែកបញ្ជូនសារ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១០០	អនុនាវីទោ	នូ ហូច	អត្តលេខ	០៤២៦៩៨	មេបញ្ជាការអ.ធ៣កងការពារកោះរ៉ុង មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១០១	អនុនាវីទោ	រឹម រ៉ម	អត្តលេខ	០១៥១៦៥	មេបញ្ជាការអ.ធ៣កងជើងទឹកវាយលើគោក មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១០២	អនុនាវីត្រី	នួន បូរ៉ា	អត្តលេខ	០៥៥៥៤១	ជំនួយការសោធននិវត្តន៍ ការិយាល័យទី១ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១០៣	អនុនាវីត្រី	ឡូច ធី	អត្តលេខ	០៣២១៣១	ជំនួយការបូកសរុប ការិយាល័យទី២ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១០៤	អនុនាវីត្រី	ឃឿង ឈុនលី	អត្តលេខ	០៥៦៨៩៦	ជំនួយការស៊ើបការការិយាល័យទី២ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១០៥	អនុនាវីត្រី	ទឹម រ៉ា	អត្តលេខ	០៤២៨៨៦	មេបញ្ជាការនាវា២៦១៨ រោងជាង បញ្ជាការដ្ឋាន កងទ័ពជើងទឹក

១០៦	អនុនាវីត្រី	ឈុំ ដារ៉ែន	អត្តលេខ	០៥៥៥៦២	នាយរងផ្នែកអ៊ូរ រោងជាង បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១០៧	អនុនាវីត្រី	ឡុង សុវណ្ណារ៉ែន	អត្តលេខ	០៣១១៧៤	មេបញ្ជាការរងធ.ធំ១ កងនាវាល្បាតទន្លេ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១០៨	អនុនាវីត្រី	សៅ សារ៉ាម	អត្តលេខ	០៤២៨៣៦	មេ.រងអ.ធំដឹកជញ្ជូន១កងនាវាល្បាតទន្លេ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១០៩	អនុនាវីត្រី	នូ សាម៉ុឌី	អត្តលេខ	០៤២៨៣៨	មេ.រងអ.ធំដឹកជញ្ជូន១កងនាវាល្បាតទន្លេ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១១០	អនុនាវីត្រី	សក់ ញ៉ី	អត្តលេខ	០៤២៨៦៤	ជំនួយការបុគ្គលិក កងនាវាល្បាតទន្លេ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១១១	អនុនាវីត្រី	ឡេង ម៉ិនសៀវ	អត្តលេខ	០៤២៧៦២	នាយកាំភ្លើងនាវា១១៣៣កងនាវាប្រដេញ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១១២	អនុនាវីត្រី	ចៅ សារ៉េត	អត្តលេខ	០៣៤៩៨៥	ជំនួយការផ្នែកវិទ្យុទាក់ទង មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១១៣	អនុនាវីត្រី	ឆេព សំអុល	អត្តលេខ	០៤២៧៥០	ជំនួយការផែនទីភូមិសាស្ត្រ ការិយាល័យទី៣ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១១៤	អនុនាវីត្រី	ឡុង ស៊ីម៉ន	អត្តលេខ	០៤២៧៤៧	ជំនួយការប្រយុទ្ធ ការិយាល័យទី៣ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១១៥	អនុនាវីត្រី	ចាន់ សំណាង	អត្តលេខ	០៥៥៨៧១	នាយរងផ្នែកបំភ័ន្តអក្ខរៈ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១១៦	អនុនាវីត្រី	អ៊ុង ខេម	អត្តលេខ	០៥៥៨៧៣	ជំនួយការស្រាវជ្រាវ ការិយាល័យទី២ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១១៧	អនុនាវីត្រី	យឹម ទីត	អត្តលេខ	០៤២៨៦០	នាយរងផ្នែកដុក១០០០តោន រោងជាង មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១១៨	អនុនាវីត្រី	ម៉ុញ សារឿន	អត្តលេខ	០៤២៧០៤	មេបញ្ជាការរងអ.ធំ៣កងការពារកោះកុងក្រៅ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១១៩	អនុនាវីត្រី	ឈឹម មុត	អត្តលេខ	០៤២៧១០	មេបញ្ជាការរងអ.ធំ៣កងការពារកោះតាង មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១២០	អនុនាវីត្រី	លាវ សារ៉េត	អត្តលេខ	០៤២៦៩១	ជំនួយការគណនេយ្យការិយាល័យហិរញ្ញវត្ថុ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១២១	អនុនាវីត្រី	សាយ ស៊ុនលី	អត្តលេខ	០៤២៧៦៥	មេ.រងនាវ១១៣៤កងនាវាប្រដេញ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១២២	អនុនាវីត្រី	ឆាយ ស៊ីថា	អត្តលេខ	០៤២៧៧២	មេបញ្ជាការនាវា១១២២កងនាវាប្រដេញ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១២៣	អនុនាវីត្រី	គីម សុផា	អត្តលេខ	០៤២៧៥៦	មេបញ្ជាការរងនាវា១១២២កងនាវាប្រដេញ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១២៤	អនុនាវីត្រី	ជួន សារ៉េត	អត្តលេខ	០៣១១៦៣	មេរងស្ថានីយ៍រ៉ាដាសង្កេតការផ្ទៃអាកាសកងរ៉ាដា មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១២៥	អនុនាវីត្រ	ម៉េន ចំណ្ណា	អត្តលេខ	០៥៥៧០០	មេបពាការរងនាវា១១០១កងនាវាល្បាតឆ្នេរ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១២៦	អនុនាវីត្រី	ទិន ស៊ុំណាត	អត្តលេខ	០៣១១៦៩	មេ.រងអ.ធំ២កងជើងទឹកវាយលើគោក មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១២៧	អនុនាវីត្រី	ប្រាក់ ឡុញ	អត្តលេខ	០៣១១៧៨	មេ.រងអ.ធំ២កងជើងទឹកវាយលើគោក មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១២៨	អនុនាវីត្រី	ជៀម សំបូរ	អត្តលេខ	០៣១១៦១	ជំនួយការប្រយុទ្ធ កងជើងទឹកវាយលើគោក មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១២៩	អនុនាវីត្រី	ជឹម សុវត្ថិ	អត្តលេខ	០៥៦០៥១	ជំនួយការឯកសារ ខុទ្ទកាល័យ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៣០	នាយនាវីចំណង់	លឿង ម៉ាន់	អត្តលេខ	១៤២៥៣១	ជំនួយការបើកបររថយន្ត ការិយាល័យទី៤ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៣១	នាយនាវីចំណង់	លី សារឿន	អត្តលេខ	០៥៥៥៣៤	ជំនួយការពិធីការ ការិយាល័យទី៥ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៣២	នាយនាវីចំណង់	មាស សាខន	អត្តលេខ	០៥៥៥៥៩	នាយរងផ្នែកនាវាវ៉េម៉ូត័រ រោងជាង បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៣៣	នាយនាវីចំណង់	ង៉ែ ស៊ីថា	អត្តលេខ	០៥៦០៤៨	មេ.រងនាវា២៩០៥អ.ធំ៣កងនាវាល្បាតទន្លេ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៣៤	នាយនាវីចំណង់	ខាង សន	អត្តលេខ	០៥៦០៣១	ជំនួយការភ័ស្តុភារ កងនាវាល្បាតទន្លេ បញ្ជាការដ្ឋាន កងទ័ពជើងទឹក

១៣៥	នាយនាវីចំណង់	ពេជ្រ សឿម	អត្តលេខ	០៤២៨៧៧	មេ.រងនាវា២៩០៣អ.ធំ២កងនាវាល្បាតទន្លេ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៣៦	នាយនាវីចំណង់	ឡុង ស៊ីធុន	អត្តលេខ	០៥៦០១៩	ជំនួយការវិទ្យុទាក់ទង កងនាវាល្បាតទន្លេ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៣៧	នាយនាវីចំណង់	ព្រាប សាំង	អត្តលេខ	០៥៥៨៥៣	ជំនួយការយន្តយុទ្ធ ការិយាល័យទី៤ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១៣៨	នាយនាវីចំណង់	ញឹម គ្រេត	អត្តលេខ	០៥៥៨៤២	ជំនួយការឯកសារ លេខាធិការដ្ឋាន មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១៣៩	នាយនាវីចំណង់	អ៊ីវ ជា	អត្តលេខ	០៧៧៨៩៦	នាយរងផ្នែកជួសជុលនាវា រោងជាង មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១៤០	នាយនាវីចំណង់	ហង្ស ចិន	អត្តលេខ	០៥៥៧៨៥	មេ.រងអ.ធំ២កងកាំភ្លើងធំការពារអាកាស មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១៤១	នាយនាវីចំណង់	ឡុងចាន់ដេត	អត្តលេខ	០៥៥៦៩៨	នាយកាំភ្លើងនាវា១១០៦កងនាវាល្បាតឆ្នេរ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១៤២	នាយនាវីចំណង់	ទង្ស មឿន	អត្តលេខ	០៥៥៧០៤	ជំនួយការផែនទីភូមិសាស្ត្រ ការិយាល័យទី៣ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១៤៣	នាយនាវីចំណង់	ជ័យ សុវណ្ណរិទ្ធ	អត្តលេខ	០៥៥៨៥០	ជំនួយការស្បៀងការិយាល័យទី៤ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១៤៤	នាយនាវីចំណង់	ផុន ផេន	អត្តលេខ	០៥៥៧៨២	ជំនួយការវិទ្យុទាក់ទង ផ្នែកបញ្ជូនសារ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១៤៥	នាយនាវីចំណង់	ពេញ ឈិន	អត្តលេខ	០៥៥៩០២	មេបញ្ជាការរងអ.ធំវិស្វកម្ម មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១៤៦	នាយនាវីចំណង់	ជេត ឫទ្ធី	អត្តលេខ	០៥៦១៤៩	ជំនួយការប្រយុទ្ធ កងជើងទឹកវាយលើគោក មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១៤៧	នាយនាវីចំណង់	ភាច តារា	អត្តលេខ	០៥៦១១២	ជំនួយការហិរញ្ញវត្ថុកងជើងទឹកវាយលើគោក មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១៤៨	នាយនាវីចំណង់	ដួង សុខា	អត្តលេខ	០៤២៨២៣	ជំនួយការហិរញ្ញវត្ថុកងជើងទឹកវាយលើគោក មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១៤៩	នាយនាវីចំណង់	សេង វដ្ឋា	អត្តលេខ	០៤២៨២៨	ជំនួយការពេទ្យបឋមកងជើងទឹកវាយលើគោក មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១៥០	នាយនាវីចំណង់	ម៉ៃហមសិតោន	អត្តលេខ	០៤២៩១៣	ជំនួយការប្រយុទ្ធ កងជើងទឹកវាយលើគោក មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១៥១	នាយចក្របាលឯក	ពេជ្រ មុន្នី	អត្តលេខ	០៥៦១៣១	ជំនួយការបូកសរុប ការិយាល័យទី៣ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៥២	នាយចក្របាលឯក	គុជ សុវណ្ណារ៉ា	អត្តលេខ	០៥៥៩៨២	ជំនួយការឃ្លាំង ការិយាល័យបច្ចេកទេស បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៥៣	នាយចក្របាលឯក	សេង ឡៃ	អត្តលេខ	០៦២៩៣៣	បុគ្គលិកវិទ្យុទាក់ទង ការិយាល័យបញ្ជូនសារ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៥៤	នាយចក្របាលឯក	អ៊ិន សារឿន	អត្តលេខ	០៦២៩៥៨	ជាងឈើ រោងជាង បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៥៥	នាយចក្របាលឯក	ជា កេន	អត្តលេខ	០៥៦១០៧	ប្រ.កាំនាវា២៦០២អ.ធំ១កនាវាល្បាតទន្លេ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៥៦	នាយចក្របាលឯក	ភាច ណារិន	អត្តលេខ	០៥៦១៣៦	បច្ចេកទេសនាវា២៦១៣អ.ធំ២កងវនាវាល្បាតទន្លេ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៥៧	នាយចក្របាលឯក	អួន ជុំ	អត្តលេខ	០៥៥៩៦៩	ប.ទនាវា២៤០១អ.ធំដឹកជញ្ជូន១កនាវាល្បាតទន្លេ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៥៨	នាយចក្របាលឯក	អ៊ូ សុធី	អត្តលេខ	០៨៤២៩១	បុគ្គលិកវិស្វកម្ម ផ្នែកវិស្វកម្ម មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១៥៩	នាយចក្របាលឯក	សំ តឿ	អត្តលេខ	០៥៥៣៦៣	បុគ្គលិកសំភារៈ ការិយាល័ហ្វឹកហ្វឺន មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១៦០	នាយចក្របាលឯក	ម៉ាល់ សុភក្តិ	អត្តលេខ	០៥៥៦៣៩	បុគ្គលិកសំភារៈ ការិយាល័ហ្វឹកហ្វឺន មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១៦១	នាយចក្របាលឯក	ជ័យ កុលពីសី	អត្តលេខ	០៥៥៨៨២	ពេទ្យបឋមគិលានដ្ឋាន មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១៦២	នាយចក្របាលឯក	កេង ស៊ីនិត	អត្តលេខ	០៨៤៤៣៣	មេបញ្ជាករអ.ត២អ.ធំ ការពារ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១៦៣	នាយចក្របាលឯក	ឆិត្ស ទី	អត្តលេខ	១៣៧៤៤៧	មេបញ្ជាការអ.ត១អ.ធំ៣កងកាំភ្លើងធំលេខ៨ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក

១៦៤	នាយចក្របាលឯក	ឡុច ថ្ងៃ	អត្តលេខ	០៦៣១៦២	បុគ្គលិកម៉ាស៊ីននាវា១១០៥កងនាវាល្បាតឆ្នេរ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១៦៥	នាយចក្របាលឯក	នុត នី	អត្តលេខ	០៧៧៨៨៨	មេបញ្ជាការអ.ត១អ.ធំ ការពារ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១៦៦	នាយចក្របាលឯក	សុខ សុធា	អត្តលេខ	០៦៣១១១	បុគ្គលិកកងការពារកោះកុងក្រៅលេខ២ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១៦៧	នាយចក្របាលឯក	តេ ជំនិត	អត្តលេខ	០៥៦០១៩	នាយទាហានរង កងជើងទឹកវាយលើគោក មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១៦៨	នាយចក្របាលឯក	ស៊ឹម មិថុនា	អត្តលេខ	០៦៣០៥៦	នាយទាហានរង កងជើងទឹកវាយលើគោក មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១៦៩	នាយចក្របាលទោ	រ័ត្ន ហ៊ីម	អត្តលេខ	០៧៧៥៦៤	ប្រធានក្រុមអ.ធំកងការពារ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៧០	នាយចក្របាលទោ	សរ សំអុល	អត្តលេខ	០៩១១២៤	ជំនួយការកង អ.ធំកងការពារ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៧១	នាយចក្របាលទោ	ម៉ោល សុខ	អត្តលេខ	០៧៧៧២៦	ប្រធានក្រុមអ.ធំកងការពារ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៧២	នាយចក្របាលទោ	ទ៉ាន់ ឈុន	អត្តលេខ	០៧៧០៩៥	អនុប្រធានប៉ុស្តិ៍អ.ធំកងការពារ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៧៣	នាយចក្របាលទោ	ម៉ុក សំណាង	អត្តលេខ	០៧៧៨២៧	កងការពារអ.ធំកងកាពារ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៧៤	នាយចក្របាលទោ	ទ្រាក់ សុផាត	អត្តលេខ	០៧៧៦១៨	អនុប្រធានប៉ុស្តិ៍អ.ធំកងការពារ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៧៥	នាយចក្របាលទោ	ហឿន ហឿង	អត្តលេខ	០៧៧៦១៦	កងការពារអ.ធំកងការពារ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៧៦	នាយចក្របាលទោ	ឃឿន សុផល	អត្តលេខ	០៧៧៧០០	ជំនួយការសំភារៈកងនាវាល្បាតទន្លេ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៧៧	នាយចក្របាលទោ	ទ្រាក់ សុខន	អត្តលេខ	០៧៧៧២១	ប.ទនាវា២៦១២អ.ធំ២កងនាវាល្បាតទន្លេ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៧៨	នាយចក្របាលទោ	សុខ នួន	អត្តលេខ	០៧៧៧១២	កាំភ្លើងនាវា២៦០៧អ.ធំដ.ជ៣កងនាវាល្បាតទន្លេ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៧៩	នាយចក្របាលទោ	នួន អន	អត្តលេខ	០៦៣១១៣	ជំនួយការចលនុប្បត្តម្ភកងការពារកោះកុងក្រៅ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១៨០	នាយចក្របាលទោ	នូ ផាន	អត្តលេខ	១៣៨៤៧០	មេបញ្ជាការអ.ត៣អ.ធំ១កងកាំភ្លើងធំលេខ៨ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១៨១	នាយចក្របាលទោ	កែន សុខុម	អត្តលេខ	០៦៣១៤៦	មេបញ្ជាការអ.ត២អ.ធំ៣កងការពារកោះពូលូវៃ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១៨២	នាយចក្របាលទោ	ម៉ៅ ទាសនា	អត្តលេខ	០៦៣១៣៤	មេបញ្ជាការរងអ.ត៣អ.ធំ២កងការពារកោះពូលូវៃ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១៨៣	នាយចក្របាលទោ	លឹម អយ	អត្តលេខ	០៧៧៨៨៦	បុគ្គលិក ផ្នែកវិស្វកម្ម មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១៨៤	នាយចក្របាលទោ	អាន ចន្ទ្រះ	អត្តលេខ	០៧៧៨៧៨	បុគ្គលិក ផ្នែកវិស្វកម្ម មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១៨៥	នាយចក្របាលទោ	ពេជ្រ ថាវី	អត្តលេខ	០៧៧៨៥៨	បុគ្គលិកឯកសារ លេខាធិការដ្ឋាន មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១៨៦	នាយចក្របាលទោ	សុខ ស្មើ	អត្តលេខ	០៦៣១៦៣	បុគ្គលិកវិទ្យុនាវា១១០៥កងនាវាល្បាតឆ្នេរ មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១៨៧	នាយចក្របាលទោ	គង់ ធឿន	អត្តលេខ	០៧៧៨២៩	នាយទាហានរង កងជើងទឹកវាយលើគោក មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក
១៨៨	ចក្របាលឯក	ជា សុធា	អត្តលេខ	០៧៧៥៦១	បំរើការ ការិយាល័យហិរញ្ញវត្ថុ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៨៩	ចក្របាលឯក	ធី ធូ	អត្តលេខ	០៨៤២៨៦	កងការពារអ.ធំកងការពារ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៩០	ចក្របាលឯក	កែវ សុខជា	អត្តលេខ	១១២៧៣៨	កាំភ្លើងនាវា២៤០៣អ.ធំដ.ជ១កងនាវាល្បាតទន្លេ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៩១	ចក្របាលទោ	សារិនកិត្យានុរិទ្ធ	អត្តលេខ	០៣៤៤១៥	ជំនួយការឃោសនា ការិយាលយទី៥ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៩២	ចក្របាលទោ	ហ៊ីម សំអឿន	អត្តលេខ	១៣៣២០៧	ប្រធានក្រុមអ.ធំកងការពារ បញ្ជាការដ្ឋាន កងទ័ពជើងទឹក

១៩៣	ចក្របាលត្រី	**អ៊ុខ ទិចិត្រា**	អត្តលេខ	១១២៨០០	កាំភ្លើងនាវា២៩០៤អ.ធំ២កងនាវាល្បាតទន្លេ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៩៤	ចក្របាលត្រី	**យិន ឈឿន**	អត្តលេខ	១១២៧៣០	កាំភ្លើងនាវា២៤០១ជ.ជ១កងនាវាល្បាតទន្លេ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៩៥	ចក្របាលត្រី	**តើយ សារ៉ុន**	អត្តលេខ	១១២៧៣៧	កាំភ្លើងនាវា២៤០៣ជ.ជ១កងនាវាល្បាតទន្លេ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៩៦	ចក្របាលរងឯក	**ហឿន ឡូញ**	អត្តលេខ	១១២៨០៤	កាំភ្លើងនាវា២៤០៩ជ.ជ៣កងនាវាល្បាតទន្លេ បញ្ជាការដ្ឋាន កងទ័ពជើងទឹក
១៩៧	ចក្របាលរងឯក	**កែវ ទិសាល**	អត្តលេខ	១១២៨៣៧	នាយទាហានរង កងជើងទឹកវាយលើគោក មូលដ្ឋានសមុទ្រ កងទ័ពជើងទឹក

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥៤០ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក និងប្រទេសបារាំង ចំនួន១៤រូប ដែលបានបរិច្ចាគធនធានផ្ទាល់ខ្លួន ជួយកសាងព្រះវិហារ សាលាបាលី ឈាបនដ្ឋាន និងសមិទ្ធផលនានាជាច្រើនទៀត នៅវត្តប្រាសាទស្រះឈ្នះ ឃុំឈ្នះមានជ័យ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោមនេះ :-

ក.មេដាយមាសស្ថាបនាជាតិ :

១-លោកស្រី **លាង សៀម** សប្បុរសជនខ្មែររស់នៅសហរដ្ឋអាមេរិក ថវិកា ២០.០៣០ ដុល្លារ

២-លោក **គីម ហាក់** ព្រមទាំងភរិយានិងបុត្រ នៅសហរដ្ឋអាមេរិក ថវិកាចំនួន ១៦.៨០៥ ដុល្លារ

ខ.មេដាយប្រាក់ស្ថាបនាជាតិ :

-លោកស្រី **ទៃ សារុន** សប្បុរសជនខ្មែរនៅសហរដ្ឋអាមេរិក ថវិកាចំនួន ៥.៩៧០ ដុល្លារ

គ.មេដាយសំរិទ្ធស្ថាបនាជាតិ :

១-លោក **យាន ហួត** ព្រមទាំងភរិយានិងបុត្រ នៅសហរដ្ឋអាមេរិក ថវិកាចំនួន ៤.៦៣៩ ដុល្លារ

២-លោក **គឹម ញាន** ព្រមទាំងភរិយានិងបុត្រ នៅសហរដ្ឋអាមេរិក ថវិកាចំនួន ៤.៣៣៥ ដុល្លារ

៣-លោកតា **ឈាង ម៉ាង** ព្រមទាំងភរិយានិងបុត្រ នៅសហរដ្ឋអាមេរិក ថវិកាចំនួន ៣.៥១០ ដុល្លារ

៤-លោក **គង់ សាអ៊ាន់** ព្រមទាំងភរិយានិងបុត្រ នៅប្រទេសបារាំង ថវិកាចំនួន ៣.០៥០ ដុល្លារ

៥-លោក	សែម ខេត្ត	ព្រមទាំងភរិយានិងបុត្រ នៅសហរដ្ឋអាមេរិក ថវិកាចំនួន	២.០០០ ដុល្លារ
៦-លោក	ផៃ ចំនួសគ្គី	ព្រមទាំងភរិយានិងបុត្រ នៅសហរដ្ឋអាមេរិក ថវិកាចំនួន	១.៥០០ ដុល្លារ
៧-លោក	ម្លូច ឡឹប	ព្រមទាំងភរិយានិងបុត្រ នៅសហរដ្ឋអាមេរិក ថវិកាចំនួន	១.៥០០ ដុល្លារ
៨-លោក	នួច គឹមយាន	ព្រមទាំងភរិយានិងបុត្រ នៅសហរដ្ឋអាមេរិក ថវិកាចំនួន	១.១៥០ ដុល្លារ
៩-លោក	កែវ ឌួន	ព្រមទាំងភរិយានិងបុត្រ នៅសហរដ្ឋអាមេរិក ថវិកាចំនួន	១.១០០ ដុល្លារ
១០-លោក	សៅ សែន	ព្រមទាំងភរិយានិងបុត្រ នៅសហរដ្ឋអាមេរិក ថវិកាចំនួន	១.០៥៥ ដុល្លារ
១១-លោក	ចាំង ថា	ព្រមទាំងភរិយានិងបុត្រ នៅសហរដ្ឋអាមេរិក ថវិកាចំនួន	១.០២៥ ដុល្លារ

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

PS.31-32

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ...៥៥១...អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ចំនួន០៧គ្រឿង ជូនសប្បុរសជន ចំនួន០៧រូប ដែលបានបរិច្ចាគថវិកាផ្ទាល់ខ្លួន ជួយកសាងព្រះវិហារ សាលាបាលី ប្រាង្គ កុដិ ផ្ទះបាយ របងវត្ត និងសមិទ្ធផលនានាជាច្រើនទៀត នៅវត្តសុវណ្ណគិរីភ្នំតូច ឃុំភ្នំតូច ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ដូចមានរាយនាមខាងក្រោមនេះ :-

ក-មេដាយមាសស្ថាបនាជាតិ :

១-ឧបាសក **ឡោ ឃិតស៊ុយ** និងឧបាសិកា **នេម គិមជូ** ថវិកាចំនួន ២៥.៣៨០ ដុល្លារ
២-លោក **ហែម ឃឿន** និងលោកស្រី **អ៊ុន យិន** ថវិកាចំនួន ៣១.០៩៨ ដុល្លារ
៣-លោក **សៅ មុនិន្ទ** និងលោកស្រី **ផាន់ ឯម** ថវិកាចំនួន ១១.០០០ ដុល្លារ
៤-លោក **សុខ ប្រាសិទ្ធិ** និងលោកស្រី **ឌុច ម៉ៃ** ថវិកាចំនួន ១១.០០០ ដុល្លារ
៥-លោក **ញឹក ឯក** និងលោកស្រី **ខៀវ សម្បត្តិ** ថវិកាចំនួន ១១.០០០ ដុល្លារ
៦-លោក **ខឹន អឿន** និងលោកស្រី **ឡឹមឡាំ តាន់ម៉ិច** ថវិកាចំនួន ១២.៩៨៧ ដុល្លារ

ខ.មេដាយគ្រាក់ស្ពាននាជាតិ :

-លោក **ហេខ មណី** និងលោកស្រី **សេ់ ណារី** ថវិកាចំនួន ៧.៣០០ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តបន្ទាយមានជ័យ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៥៥៧...អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងធម្មការ និង សាសនា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេននិងជូនសប្បុរសជន ចំនួន០៧រូប ដែលបានបរិច្ចាគបច្ច័យនិងថវិកា ចូលរួមជួយកសាងព្រះវិហារ ០១ខ្នង និង កុដិ ០១ខ្នង នៅក្នុងពុទ្ធសីមាវត្តតាំងក្រសាំងខាងជើង សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ ដូចមានរាយព្រះនាមនិងនាមខាងក្រោមនេះ :-

ក.មេដាយមាសស្ថាបនាជាតិ :

១-ព្រះគ្រូរក្ខិតទេវី **ចាន់ ស៊ី** ចៅអធិការវត្តតាំងក្រសាំងខាងជើង បច្ច័យ ៤៥.៩១៣.២៨ ដុល្លារ

២-ឧបាសិកា **ស៊ុយ សាន** សប្បុរសជន ថវិកា ១២.១៥៩ ដុល្លារ

ខ.មេដាយប្រាក់ស្ថាបនាជាតិ :

១-ភិក្ខុ **ចាន់ សុភី** គ្រូសូត្រស្តាំវត្តតាំងក្រសាំងខាងជើង បច្ច័យ ៧.៣៩០ ដុល្លារ

២-ភិក្ខុ **គីម គួន** គ្រូសូត្រឆ្វេងវត្តតាំងក្រសាំងខាងជើង បច្ច័យ ៦.៤៦៧ ដុល្លារ

៣-លោក **នឹម ចន្ថា** សប្បុរសជន ថវិកា ៥.២៧៥ ដុល្លារ

៤-លោក	**ហែម និមល**	ប្រធានគណៈកម្មការវត្ត	ថវិកា ៥.១២៥ ដុល្លារ
៥-លោកវេជ្ជបណ្ឌិត	**សុខ កុសល**	សប្បុរសជន	ថវិកា ៥.២១៦ ដុល្លារ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា និង អភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/-

រាជធានីភ្នំពេញ ថ្ងៃទី ១៥ កក្កដា ឆ្នាំ ២០០៥

ហ៊ុន សែន

__កន្លែងទទួល__ :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ

PS.50-51

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ ៖ ៦៨ សសរ

សេចក្តីសម្រេច

ស្តីពី

ការបង្កើតគណៈកម្មការធ្វើវិវេចនា

លើសេចក្តីព្រាងសៀវភៅ ស ការពារជាតិ ២០០៥

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស /រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០១/២៣៧ ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០០១ ស្តីពីការកែសំរួលតួនាទី ភារៈកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការកែសំរួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ
- បានឃើញសេចក្តីសំរេចលេខ ០២៥/០៥ សសរ ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៤ របស់ក្រសួងការពារជាតិ ស្តីពីការបង្កើតក្រុមការងារសៀវភៅ ស ការពារជាតិ ២០០៤
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

សម្រេច

ប្រការ ១ :

បង្កើតគណៈកម្មការមួយមានឈ្មោះថា គណៈកម្មការធ្វើវិវេចនាលើសេចក្តីព្រាងសៀវភៅ ស ការពារជាតិ ដែលមានសមាសភាពដូចខាងក្រោម :

១- សហរដ្ឋមន្ត្រីក្រសួងការពារជាតិ	ជាសហប្រធាន
២- អគ្គមេបញ្ជាការ នៃកងយោធពលខេមរភូមិន្ទ	ជាអនុប្រធាន
៣- ប្រធានក្រុមការងារអនុវត្តគោលការណ៍សៀវភៅ ស ការពារជាតិ ២០០៥	ជាអនុប្រធាន
៤- ប្រធានក្រុមការងារសៀវភៅ ស ការពារជាតិ ២០០៥	ជាសមាជិកអចិន្ត្រៃយ៍
៥- មេបញ្ជាការកងទ័ពជើងគោក	ជាសមាជិក
៦- មេបញ្ជាការកងទ័ពជើងទឹក	ជាសមាជិក
៧- មេបញ្ជាការកងទ័ពជើងអាកាស	ជាសមាជិក
៨- មេបញ្ជាការកងរាជអាវុធហត្ថ	ជាសមាជិក
៩- អគ្គលេខាធិការក្រសួងការពារជាតិ	ជាសមាជិក
១០- អគ្គនាយក អគ្គនាយកដ្ឋានភស្តុភារ-ហិរញ្ញវត្ថុ	ជាសមាជិក
១១- អគ្គនាយក អគ្គនាយកដ្ឋានយោធសេវា	ជាសមាជិក
១២- អគ្គនាយក អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស	ជាសមាជិក
១៣- នាយកខុទ្ទកាល័យ អគ្គបញ្ជាការដ្ឋាន	ជាសមាជិក
១៤- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	ជាសមាជិក
១៥- តំណាងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	ជាសមាជិក
១៦- តំណាងក្រសួងមហាផ្ទៃ	ជាសមាជិក
១៧- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	ជាសមាជិក
១៨- តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	ជាសមាជិក
១៩- តំណាងក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ	ជាសមាជិក
២០- តំណាងក្រសួងបរិស្ថាន	ជាសមាជិក
២១- តំណាងខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី	ជាសមាជិក
២២- នាយក នាយកដ្ឋានទាក់ទងអន្តរជាតិ ក្រសួងការពារជាតិ	ជាសមាជិក

ប្រការ ២ :

គណៈកម្មការនេះមានភារកិច្ចពិនិត្យសើរើ និងសិក្សាលើសេចក្តីព្រាងឯកសារសៀវភៅ ស ការពារជាតិ ដែលបានតាក់តែងដោយក្រុមការងារសៀវភៅ ស ការពារជាតិ ២០០៥ ព្រមទាំងធ្វើការកែលំអឯកសារនេះឱ្យមាន

លក្ខណៈសមស្របទៅនឹងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដោយផ្អែកលើមាគ៌ានយោបាយសន្តិសុខជាតិ របស់រាជរដ្ឋាភិបាលជាមូលដ្ឋាននិងឆ្លើយតបទៅនឹងផែនការអភិវឌ្ឍន៍កងកម្លាំងប្រដាប់អាវុធ នៃកងយោធពលខេមរភូមិន្ទ ។

ប្រការ ៣ :

សមាជិកនៃគណៈកម្មការនេះ ត្រូវចូលរួមប្រជុំការងារតាមការកោះអញ្ជើញរបស់សហប្រធាន ។

ប្រការ ៤ :

បន្ទាប់ពីមានការឯកភាពទៅលើចំណុចទាំងអស់ នៃសេចក្តីព្រាងឯកសារសៀវភៅ ស នេះហើយ គណៈកម្មការត្រូវស្នើសុំសច្ចាប័នពីរាជរដ្ឋាភិបាល មុនពេលដែលឯកសារនេះត្រូវចេញផ្សាយជាផ្លូវការ ។

ប្រការ ៥ :

គណៈកម្មការនេះមានសិទ្ធិប្រើត្រារបស់ក្រសួងការពារជាតិ សំរាប់ដំណើរការអនុវត្តការងាររបស់ខ្លួន ។

ប្រការ ៦ :

ក្រោយពីបានទទួលសេចក្តីសំរេចនេះ គ្រប់ក្រសួង ស្ថាប័ន ពាក់ព័ន្ធត្រូវប្រញាប់ផ្ញើឈ្មោះតំណាង ០១រូប ដែលមានឋានៈចាប់ពី អនុរដ្ឋលេខាធិការឡើងទៅ (ឈ្មោះ ឋានៈ មុខតំណែង លេខទូរស័ព្ទ) ឱ្យទៅអគ្គលេខាធិការដ្ឋានក្រសួងការពារជាតិ ដើម្បីងាយស្រួលក្នុងការអញ្ជើញចូលរួមប្រជុំ និងទំនាក់ទំនងកិច្ចការនេះ ។

ប្រការ ៧ :

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួងពាក់ព័ន្ធ ព្រមទាំងសមាសភាពដែលមានចែងក្នុងប្រការ ១ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាពខ្ពស់ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
  (ដើម្បីជូនជ្រាប)
- *ដូចប្រការ ៧*
  (ដើម្បីអនុវត្ត)
- *ឯកសារ_កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ...៦៩...សសរ...

សេចក្តីសំរេច

ស្តីពី

ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសិក្សាស្រាវជ្រាវករណីស្នើសុំសាងសង់ស្ពានបេតុងសំរាប់ថ្មើរជើងឆ្លងកាត់ផ្លូវវិថីធំៗ ដែលមានចរាចរកកស្ទះក្នុងរាជធានីភ្នំពេញរបស់ក្រុមហ៊ុន Cambodia quarry

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

ប្រការ១ : បង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីចុះពិនិត្យសិក្សាស្រាវជ្រាវអំពីការស្នើសុំសាងសង់ស្ពានបេតុងសំរាប់ថ្មើរជើងឆ្លងកាត់ផ្លូវវិថីធំៗ ដែលមានចរាចរកកស្ទះ ក្នុងរាជធានីភ្នំពេញរបស់ក្រុមហ៊ុន Cambodia quarry ដែលមានសមាសភាពដូចខាងក្រោម :-

១- តំណាងក្រសួងមហាផ្ទៃ	ប្រធាន
២- តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន	អនុប្រធាន
៣- តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់	សមាជិក
៤- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក
៥- តំណាងអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	សមាជិក
៦- តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ	សមាជិក

៧- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក

៨- តំណាងក្រសួងបរិស្ថាន សមាជិក

៩- តំណាងសាលាក្រុងភ្នំពេញ សមាជិក

ប្រការ២ : គណៈកម្មការអន្តរក្រសួងនេះមានភារកិច្ចដូចតទៅ :

- ចុះពិនិត្យសិក្សាស្រាវជ្រាវស៊ីជំរៅដល់ទីកន្លែង ដែលស្នើសុំសាងសង់ស្ពានបេតុងសំរាប់ ថ្មើរជើងឆ្លងកាត់ផងវិថីធំៗទាំង ០៣ កន្លែងនោះ
- ពិនិត្យលើគំរោងសាងសង់របស់សាម៉ីក្រុមហ៊ុន
- វាយតម្លៃអំពីហេតុផលប៉ះពាល់ដល់បរិស្ថាន និងលំនៅស្ថានប្រជាជន
- ធ្វើរបាយការណ៍សរុបលទ្ធផលការងារ និងលើកវិធានការ ព្រមទាំងសំណូមពរជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសំរេច ។

ប្រការ៣ : សមាជិកគណៈកម្មការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។

ប្រការ៤ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងបរិស្ថាន អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា អភិបាលក្រុងភ្នំពេញ និងគណៈកម្មការ ដូចមានចែងក្នុងប្រការ ១ ខាងលើត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ដូចប្រការ ៤
- ឯកសារ- កាលប្បវត្តិ

C:\ardin\Samrech.doc

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..៧០....សសរ

សេចក្តីសម្រេច

ស្តីពី

ការបង្កើតក្រុមការងារកម្ពុជា ប្រឆាំងអំពើជួញដូរមនុស្ស នៅមហាអនុតំបន់មេគង្គ

* * * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានឃើញអនុសញ្ញាស្តីពី ការលុបបំបាត់រាល់ទំរង់ នៃការរើសអើងប្រឆាំងនឹងនារីភេទ ដែលប្រទេសកម្ពុជាបានចុះហត្ថលេខានៅថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ១៩៩២ និង ផ្តល់សច្ចាប័ននៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២
- បានឃើញអនុសញ្ញាស្តីពី សិទ្ធិកុមារ ដែលប្រទេសកម្ពុជាបានចុះហត្ថលេខានៅថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ១៩៩២ និងផ្តល់សច្ចាប័ននៅថ្ងៃទី ១៥ ខែ តុលា ឆ្នាំ ១៩៩២
- យោងតាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងកិច្ចការនារី ។

សម្រេច

ប្រការ ១.-

បង្កើតក្រុមការងារកម្ពុជា (Cambodian COMMIT Task force) ប្រឆាំងអំពើជួញដូរមនុស្ស នៅមហាអនុតំបន់មេគង្គ ដោយមានសមាសភាពដូចខាងក្រោម :

១-	លោកជំទាវ **យូ អយ** រដ្ឋលេខាធិការ ក្រសួងកិច្ចការនារី	ប្រធាន
២-	ឯកឧត្តម **អ៊ិត រ៉ាឌី** អនុរដ្ឋលេខាធិការ ក្រសួងយុត្តិធម៌	អនុប្រធាន
៣-	លោក **ឌួច សាម៉ុន** អគ្គនាយករង អគ្គនាយកដ្ឋានបច្ចេកទេស ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា	អនុប្រធាន
៤-	លោកជំទាវ **សាន្ត អរុណា** អនុរដ្ឋលេខាធិការ ក្រសួងកិច្ចការនារី	សមាជិក
៥-	ឯកឧត្តម **អៀ ម៉េងទ្រី** អនុប្រធានគណៈកម្មាធិការជាតិប្រជាជន និងការអភិវឌ្ឍន៍ ទីស្ដីការគណៈរដ្ឋមន្ត្រី	សមាជិក
៦-	លោកស្រីឧត្តមសេនីយ៍ត្រី **អ៊ិន សុគន្ធា** ប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និង ការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ	សមាជិក
៧-	ឧត្តមសេនីយ៍ត្រី **អ៊ុច សំណាង** នាយរងសេនាធិការ នៃកងរាជអាវុធហត្ថលើផ្ទៃប្រទេស	សមាជិក
៨-	លោក **យ៉េង ច័ន** ប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍ ក្រសួងទេសចរណ៍	សមាជិក
៩-	លោកស្រី **ញឹម ច័ាន់ចន្ទតន** អគ្គាធិការរង នៃអគ្គាធិការដ្ឋាន ក្រសួងអប់រំ យុវជន និង កីឡា	សមាជិក
១០-	លោក **គីម សុវណ្ណា** អនុប្រធាននាយកដ្ឋានច្បាប់ និង កុងស៊ុល ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ	សមាជិក
១១-	លោកស្រី **ហេង ស៊ីថុន** ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស ក្រសួងកិច្ចការនារី	លេខាធិការអចិន្ត្រៃយ៍

ក្រុមការងារកម្ពុជានេះ មានលេខាធិការដ្ឋានអចិន្ត្រៃយ៍ ស្ថិតនៅនាយកដ្ឋានការពារផ្លូវច្បាប់ នៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍សង្គម នៃក្រសួងកិច្ចការនារី ។ ក្រុមការងារកម្ពុជានេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងកិច្ចការនារី ដើម្បីដំណើរការការងារ ។

ប្រការ ២.-

ក្រុមការងារកម្ពុជាមានភារកិច្ចដូចតទៅ :

- សហការជាមួយលេខាធិការដ្ឋាន គំរោងអន្តរភ្នាក់ងារសហប្រជាជាតិស្តីពី ការជួញដូរមនុស្សនៅក្នុងមហាអនុតំបន់មេគង្គ UN Inter-Agency Project on Human Trafficking in the greater Mekong Sub-Region (UNIAP-C) ប្រចាំកម្ពុជា ប្រចាំទីក្រុងបាងកក និងជាមួយបណ្តាដៃគូដទៃទៀត ក្នុងការសម្របសម្រួលរាល់សកម្មភាពថ្នាក់ជាតិ និងថ្នាក់តំបន់
- រៀបចំផែនការសកម្មភាពថ្នាក់មហាអនុតំបន់ ឆ្នាំ២០០៥-២០០៧ ដើម្បីប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ពិសេសការជួញដូរស្ត្រី និង កុមារ ដោយប្រមូលផ្តុំនូវកិច្ចខិតខំប្រឹងប្រែងចាំបាច់នានា ដើម្បីប្រែក្លាយផែនការសកម្មភាពនេះជាការអនុវត្តជាក់ស្តែង
- ជំរុញការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាស្តីពី កិច្ចសហប្រតិបត្តិការប្រឆាំងអំពើជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គអោយបានពេញលេញ និង មានប្រសិទ្ធភាព
- ពង្រឹងកិច្ចសហប្រតិបត្តិការថ្នាក់មហាអនុតំបន់ និងជាមួយអង្គការក្រៅរដ្ឋាភិបាលជាតិ អន្តរជាតិ និង អង្គការអន្តរជាតិក្នុងការគៀងគរជំនួយដើម្បីអនុវត្តផែនការសកម្មភាពមហាអនុតំបន់
- ពិនិត្យតាមដាននិងវាយតម្លៃ ការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីកិច្ចសហប្រតិបត្តិការប្រឆាំងអំពើជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គ និង រាយការណ៍ជូនរាជរដ្ឋាភិបាល
- ពិនិត្យឡើងវិញនូវការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នាស្តីពី កិច្ចសហប្រតិបត្តិការប្រឆាំងអំពើជួញដូរមនុស្សនៅមហាអនុតំបន់មេគង្គរៀងរាល់ ៣ ឆ្នាំម្តង ហើយរាយការណ៍ជូនរាជរដ្ឋាភិបាល ។

ប្រការ ៣.-

ក្រុមការងារកម្ពុជា មានសិទ្ធិស្នើសុំជំនួយបច្ចេកទេស អ្នកជំនាញការអន្តរជាតិតាមការចាំបាច់ដើម្បីជួយបណ្តុះបណ្តាល និងជួយតាមដាន វាយតម្លៃការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នា ។

ប្រការ ៤.-

សមាជិកក្រុមការងារកម្ពុជា ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។ ក្នុងករណីចាំបាច់ ប្រធានក្រុមការងារអាចអញ្ជើញតំណាងក្រសួងពាក់ព័ន្ធចូលរួមប្រជុំ ។

ប្រការ ៥.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្ដីសម្រេចនេះត្រូវទុកជានិរាករណ៍ ។

ប្រការ ៦.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី រដ្ឋមន្ត្រី រដ្ឋលេខាធិការក្រសួងពាក់ព័ន្ធ និង បណ្ដាសមាសភាពដូចមានចែងក្នុងប្រការ ១ មានភារកិច្ចអនុវត្តសេចក្ដីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ដូចប្រការ ៦
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៧១ សសរ

សេចក្តីសម្រេច
ស្តីពី
ការកែសម្រួលសមាសភាពក្រុមការងារបច្ចេកទេសចំរុះ
រាជរដ្ឋាភិបាល-ប្រទេសម្ចាស់ជំនួយ លើវិស័យមីន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៧០៤ /១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០៥/២៦៥ ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ ស្តីពីវិសោធនកម្ម មាត្រា ៤ មាត្រា ១០ និងមាត្រា ១៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៩០០/១៦០ ចុះថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ ២០០០ ស្តីពីការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន
- បានឃើញសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ចុះថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបង្កើតក្រុមការងារបច្ចេកទេសចំរុះរាជរដ្ឋាភិបាល-ប្រទេសម្ចាស់ជំនួយ លើវិស័យមីន
- យោងតាមតំរូវការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

ប្រការ ១: ត្រូវបានតែងតាំង និងកែសំរួលសមាសភាពក្រុមការងារបច្ចេកទេសចំរុះរាជរដ្ឋាភិបាល ប្រទេសម្ចាស់ជំនួយ លើវិស័យមីន ដូចខាងក្រោម :

១. ឯកឧត្តម **យ៉េង ម៉ារ៉ឌី** អគ្គលេខាធិការរងអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ជាសមាជិកក្រុមការងារបច្ចេកទេសចំរុះ ជំនួសឯកឧត្តម ខឹម សោភ័ណ

២. ឯកឧត្តម ហេង រតនា អគ្គនាយករង មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា ដែលជាសមាជិកក្រុមការងារបច្ចេកទេសចំរុះ មកជា *អ្នកសង្កេតការណ៍*វិញ

ប្រការ ២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា និងសាមីខ្លួនដែលមាននាមក្នុងប្រការ ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ តាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

- ដូចប្រការ ២

- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០៥ សហវ.ទាន

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែកក្កដា ឆ្នាំ ២០០៥

សារាចរណែនាំ
ស្តីពី
ការអនុវត្តន៍នីតិវិធីកាត់ទុកប្រាក់ពន្ធនៃកិច្ចលទ្ធកម្ម

អនុលោមតាមខ្លឹមសារប្រកាសលេខ ១៦១ សហវ. ពដ ចុះថ្ងៃទី ១៥ ខែ មិនា ឆ្នាំ២០០៥ ស្តីពីកាតព្វកិច្ចសារពើពន្ធនៃកិច្ចលទ្ធកម្ម និង ដើម្បីសំរួលដល់កិច្ចបញ្ជីការបង់ប្រាក់ចូលថវិការដ្ឋ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុសូមធ្វើការណែនាំដូចខាងក្រោម:

១- ការិយាល័យគ្រប់គ្រងអ្នកជាប់ពន្ធធំនិងមធ្យម និងសាខាពន្ធដារគ្រប់ខេត្ត-ក្រុង ត្រូវស្នើសុំបើកគណនីចំណូលបណ្តោះអាសន្នពន្ធដារ នៅរតនាគារជាតិ គណនីលេខ ៤៧១.១ និង នៅរតនាគារខេត្ត-ក្រុង គណនីលេខ ៤៧១.២ ។

២- សំណុំឯកសារស្នើសុំទូទាត់ថ្លៃទំនិញឬសេវា ត្រូវមានភ្ជាប់ជាមួយនូវប័ណ្ណប៉ាតង់ ។ ការកាត់ទុកប្រាក់ពន្ធពីអាណត្តិបើកប្រាក់ រតនាគារត្រូវធ្វើការកាត់ទុកប្រាក់ពន្ធដោយផ្អែកលើមូលដ្ឋានប័ណ្ណប៉ាតង់ ដើម្បីកំណត់ការកាត់យកប្រាក់ពន្ធ ។ បើប័ណ្ណប៉ាតង់ដែលមានលេខអត្តសញ្ញាណកម្មសារពើពន្ធ គឺជាប័ណ្ណប៉ាតង់របស់អ្នកជាប់ពន្ធតាមរបបពិត តែបើនៅក្នុងប័ណ្ណប៉ាតង់ពុំមានលេខអត្តសញ្ញាណកម្មសារពើពន្ធនោះទេ គឺជាប័ណ្ណប៉ាតង់របស់អ្នកជាប់ពន្ធតាមរបបម៉ៅការ ។

៣- ប្រាក់ពន្ធដែលបានកាត់ទុកពីអាណត្តិបើកប្រាក់ដោយរតនាគារជាតិ ឬ រតនាគារខេត្ត-ក្រុង ត្រូវផ្ទេរចូលក្នុងគណនីចំណូលបណ្តោះអាសន្នពន្ធដារ (៤៧១.១) ឬ (៤៧១.២) រក្សាទុកជូនការិយាល័យគ្រប់គ្រងអ្នកជាប់ពន្ធធំ និងមធ្យម ឬសាខាពន្ធដារខេត្ត-ក្រុង និងអ្នកជាប់ពន្ធ ។ រតនាគារជាតិ ឬរតនាគារខេត្ត-ក្រុង ត្រូវធ្វើប្រកាសឥណទានស្តីពីចំនួនប្រាក់ពន្ធទាំងនោះជូនទៅការិយាល័យគ្រប់គ្រងអ្នកជាប់ពន្ធធំ និងមធ្យម ឬសាខាពន្ធដារខេត្ត-ក្រុង ។

៤- ការិយាល័យគ្រប់គ្រងអ្នកជាប់ពន្ធធំនិងមធ្យម ឬសាខាពន្ធដារខេត្ត-ក្រុង ពេលទទួលបានប្រកាសឥណទានពីរតនាគារជាតិ ឬ រតនាគារខេត្ត-ក្រុងរួចហើយ ត្រូវធ្វើការពិនិត្យមើលដើម្បីឱ្យដឹងថាទឹកប្រាក់ពន្ធរបស់អ្នកជាប់ពន្ធស្ថិតនៅក្នុងខេត្ត-ក្រុងរបស់ខ្លួន ឬជារបស់អ្នកជាប់ពន្ធដែលស្ថិតនៅក្នុងខេត្ត-ក្រុងផ្សេង ។ បើទឹកប្រាក់ពន្ធទាំងនេះជារបស់អ្នកជាប់ពន្ធដែលស្ថិតនៅក្នុងការគ្រប់គ្រងរបស់ការិយាល័យ ឬរបស់សាខាពន្ធដារខេត្ត-ក្រុងខ្លួន ការិយាល័យ ឬសាខាពន្ធដារខេត្ត-ក្រុងនោះត្រូវផ្តល់បង្កាន់ដៃពន្ធជូនទៅអ្នកជាប់ពន្ធ និងត្រូវធ្វើសលាកប័ត្របង់ប្រាក់ចំណូលចូលថវិការដ្ឋ (គណនីលេខ ៩០០) ។ បើទឹកប្រាក់ពន្ធទាំងនេះជារបស់អ្នកជាប់ពន្ធដែលមិនស្ថិតនៅក្នុងការគ្រប់គ្រងរបស់ការិយាល័យ ឬរបស់សាខាពន្ធដារខេត្ត-ក្រុងខ្លួនទេនោះ ការិយាល័យគ្រប់គ្រងអ្នកជាប់ពន្ធធំ និងមធ្យមនៅភ្នំពេញ ត្រូវធ្វើប័ណ្ណផ្ទេរភារៈចំណាយទៅរតនាគារជាតិ សាខាពន្ធដារ

ខេត្ត-ក្រុង ត្រូវធ្វើប័ណ្ណផ្ទេរភារៈចំណាយទៅរតនាគារខេត្ត-ក្រុង ដើម្បីសុំផ្ទេរប្រាក់ពន្ធនោះទៅឱ្យការិយាល័យ ឬសាខាពន្ធដារខេត្ត-ក្រុង ដែលគ្រប់គ្រងអ្នកជាប់ពន្ធនោះ ។

៥- ករណីផ្ទេរប្រាក់ពន្ធពីថ្នាក់កណ្តាលទៅខេត្ត-ក្រុង ការិយាល័យគ្រប់គ្រងអ្នកជាប់ពន្ធធំ និងមធ្យម ត្រូវធ្វើប័ណ្ណផ្ទេរភារៈចំណាយជូនទៅរតនាគារជាតិ ។ រតនាគារជាតិត្រូវប្រគល់ប័ណ្ណផ្ទេរភារៈចំណាយមួយច្បាប់ ព្រមទាំងប័ណ្ណផ្ទេរភារៈចំណាយ និងប្រកាសឥណទានដែលដាក់ក្នុងស្រោមសំបុត្របិទជិតទៅឱ្យការិយាល័យគ្រប់គ្រងអ្នកជាប់ពន្ធធំ និងមធ្យមដែលជាសាមីអ្នកស្នើសុំ ។ ការិយាល័យគ្រប់គ្រងអ្នកជាប់ពន្ធធំ និងមធ្យម ត្រូវយកឯកសារក្នុងស្រោមសំបុត្រទៅប្រគល់ជូនរតនាគារខេត្ត-ក្រុង ដែលពាក់ព័ន្ធ ដើម្បីកត់ត្រាទៅក្នុងគណនីចំណូលបណ្តោះអាសន្នរបស់សាខាពន្ធដារ (គណនីលេខ ៤៧១) ដែលជាអ្នកទទួលប្រាក់ពន្ធ ហើយជូនដំណឹងទៅសាខាពន្ធដារនោះ ដើម្បីរៀបចំសលាកប័ត្របង់ចំណូលថវិកា (គណនីលេខ ៩០០) ។

៦- ករណីផ្ទេរប្រាក់ពន្ធពីខេត្ត-ក្រុងមួយ ទៅខេត្ត-ក្រុងមួយផ្សេងទៀត សាខាពន្ធដារខេត្ត-ក្រុង ត្រូវធ្វើប័ណ្ណផ្ទេរភារៈចំណាយស្នើសុំផ្ទេរប្រាក់ពន្ធជូនទៅរតនាគារខេត្ត-ក្រុងសាមី ។ រតនាគារខេត្ត-ក្រុង ត្រូវប្រគល់ប័ណ្ណផ្ទេរភារៈចំណាយមួយច្បាប់ ព្រមទាំងប័ណ្ណផ្ទេរភារៈចំណាយនិងប្រកាសឥណទានដែលដាក់ក្នុងស្រោមសំបុត្របិទជិតទៅឱ្យសាខាពន្ធដារដែលជាអ្នកស្នើសុំផ្ទេរ ។ សាខាពន្ធដារដែលជាអ្នកស្នើសុំ ត្រូវបញ្ជូនឯកសារនៅក្នុងស្រោមសំបុត្រមករតនាគារជាតិដើម្បីចុះបញ្ជី ។ រតនាគារជាតិត្រូវរៀបចំប្រកាសឥណទានមួយថ្មីដាក់ក្នុងស្រោមសំបុត្រ រួចប្រគល់ជូនទៅសាខាពន្ធដារដែលត្រូវទទួលប្រាក់ពន្ធតាមរយៈនាយកដ្ឋានពន្ធដារ ។ ក្រោយពីបានទទួលប័ណ្ណផ្ទេរភារៈចំណាយ និងប្រកាសឥណទាន រតនាគារខេត្ត-ក្រុង ត្រូវកត់ត្រាទៅក្នុងគណនីចំណូលបណ្តោះអាសន្នរបស់សាខាពន្ធដារ (គណនីលេខ ៤៧១) ដែលជាអ្នកទទួលប្រាក់ពន្ធ ហើយជូនដំណឹងទៅសាខាពន្ធដារនោះ ដើម្បីរៀបចំសលាកប័ត្របង់ចំណូលថវិកា (គណនីលេខ ៩០០) ។

ទទួលបានសារាចរណែនាំនេះ សូមឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរតនាគារជាតិ លោកប្រធាននាយកដ្ឋានពន្ធដារ ចាត់ចែងអនុវត្តអោយទទួលបាននូវប្រសិទ្ធភាពខ្ពស់ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

<u>ចំលងជូន</u> :
- ខុទ្ទកាល័យទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- សាលាខេត្ត-ក្រុង "ដើម្បីជូនជ្រាប"
- រតនាគារខេត្ត-ក្រុង
- សាខាពន្ធដារខេត្ត-ក្រុង
"ដើម្បីអនុវត្ត"
- ឯកសារ - កាលប្បវត្តិ